**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស
ភាគីដាក់ឯកសារ: សហមេធាវី
ដាក់ជូន: សហចៅក្រមស៊ើបអង្កេត
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-May-2013, 10:02
CMS/CFO: Phok Chanthan

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់បំផុត
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សម្ងាត់បំផុត/Strictly Confidential**
ចំណាត់ថ្នាក់ប្រភេទឯកសារ **ប្តូរទៅជាសាធារណៈ**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**លិខិតសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់**
**និង**
**សារណាឆ្លើយតបរបស់សហមេធាវីទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីចំនួនផលប្រយោជន៍របស់មេធាវីដែលបានទទួលការតែងតាំង**

---

**ដាក់ដោយ:**

**សហមេធាវី**
អាង ឧត្តម
Michael G. KARNAVAS

**ផ្ញើជូន:**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ:**
**ចៅក្រម Mark HARMON**

**សហព្រះរាជអាជ្ញាអន្តរជាតិ:**
Andrew CAYLEY

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

**អង្គភាពគាំពារការការពារក្តី៖**
Isaac ENDELEY

**ចម្លងជូន៖**

**សហចៅក្រមស៊ើបអង្កេតជាតិ៖**

**ចៅក្រម យូ ប៊ុនឡេង**

**សហព្រះរាជអាជ្ញាជាតិ៖**

**ជា លាង**

០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

<u>**លិខិតសុំការអនុញ្ញាត**</u>

លោក អាង ឧត្តម និង លោក Michael G. KARNAVAS (“សហមេធាវី”) ស្នើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រដែលបានកំណត់ក្នុងការដាក់សារណាតបរបស់ខ្លួន ទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាទៅលើទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលបានទទួលការតែងតាំង។ ប្រសិនបើលិខិតសុំការអនុញ្ញាតនេះត្រូវបានបដិសេធមិនទទួលយក សហមេធាវីស្នើសុំបន្ថែមពេលវេលាចំនួនមួយថ្ងៃ ដើម្បីកោសលុប និងកែសម្រួលសារណាឆ្លើយតបដែលភ្ជាប់មកជាមួយ។ ដោយសារបញ្ហាគតិយុត្តិដែលពាក់ព័ន្ធនឹងសារណាទាំងនេះជាបញ្ហាបន្ទាន់នោះ សហមេធាវីស្នើសុំការអនុញ្ញាតដាក់សារណានេះជាភាសាអង់គ្លេសសិន ហើយយើងខ្ញុំនឹងដាក់សំណៅជាភាសាខ្មែរតាមក្រោយ ក្នុងពេលឆាប់បំផុតដែលខ្លួនអាចធ្វើបាន អនុលោមតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារ។

សូមលោកចៅក្រមមេត្តាទទួលយកលិខិតសុំការអនុញ្ញាតនេះដោយគោរព។

| | |
|---|---|
| ________________ | ________________ |
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅ**ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣**

## សារណាឆ្លើយតប

លោក អាង ឧត្តម និង លោក Michael G. KARNAVAS ("សហមេធាវី") អនុលោមតាមសេចក្តីសម្រេចលើកទី២ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងដីកាកំណត់កាលបរិច្ឆេទជាថ្មីពាក់ព័ន្ធនឹងសំណើសុំតែងតាំងសហមេធាវីដែលបានទទួលការតែងតាំង ("សេចក្តីសម្រេចលើកទី២ និង ដីកាកំណត់កាលបរិច្ឆេទជាថ្មី")[1] តទៅនេះសូមឆ្លើយតប[2] ទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាទៅលើទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលបានទទួលការតែងតាំង ("សេចក្តីសន្និដ្ឋានបន្ថែម")[3]។ ដោយសារសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា ការតែងតាំងសហមេធាវីដែលបានទទួលការតែងតាំងសម្រាប់ការពារក្តីមួយរួចហើយត្រូវបានបដិសេធ ដោយផ្អែកលើទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបាន ("សំណើ")[4] សេចក្តីសន្និដ្ឋានបន្ថែមនេះត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិគឺលោក Cayley តែម្នាក់ឯង ដោយសហព្រះរាជអាជ្ញាជាតិលោកស្រី ជា លាង មិនបានបង្ហាញជំហររបស់ខ្លួនទៅលើទឡ្ហីករណ៍អង្គច្បាប់ និងអង្គហេតុ ដែលបានលើកឡើងសមភាគីអន្តរជាតិរបស់លោកស្រីទេ[5]។ ស្រដៀងគ្នាដែរ សេចក្តីសម្រេចលើកទី២ និង ដីកាកំណត់កាលបរិច្ឆេទជាថ្មី ក៏ដូចជាដីកាកំណត់កាលបរិច្ឆេទទីមួយ[6] ដែរ គឺត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិលោកចៅក្រម Mark Harmon តែម្នាក់ឯង ដោយសហចៅក្រមស៊ើបអង្កេតជាតិលោកចៅក្រម យូ ប៊ុនឡេង មិនបានបង្ហាញ

---

[1] សេចក្តីសម្រេចលើកទី២ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងដីកាកំណត់កាលបរិច្ឆេទជាថ្មីពាក់ព័ន្ធនឹងសំណើសុំតែងតាំងសហមេធាវីដែលបានទទួលការតែងតាំង, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D56/5។

[2] តទៅនេះហៅថា "សារណាឆ្លើយតបបន្ថែម"។

[3] សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាទៅលើទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលបានទទួលការតែងតាំង, ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៣, ឯកសារ D56/7។

[4] សំណើដែលថា ការតែងតាំងសហមេធាវីដែលបានទទួលការតែងតាំងត្រូវបានបដិសេធដោយផ្អែកលើទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបាន, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ D56/1។

[5] ទាំងសំណើ ទាំងសេចក្តីសន្និដ្ឋានបន្ថែមពុំមានហត្ថលេខារបស់សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង ទេ។ ការពិតសំណើនេះកំណត់ថា គេគ្រាន់តែចម្លងជូនលោកស្រីនូវសេចក្តីសន្និដ្ឋាននោះតែប៉ុណ្ណោះ តែទំនងជាបង្ហាញថាសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley និងបុគ្គលិកអន្តរជាតិរបស់គាត់កំពុងបំពេញការងារដោយពុំមានការចូលរួម ឬការអនុម័តិនានាពីសមភាគីរបស់គាត់ទេ។

[6] សេចក្តីសម្រេច និង ដីកាកំណត់កាលបរិច្ឆេទជាថ្មីពាក់ព័ន្ធនឹងសំណើសុំតែងតាំងសហមេធាវីដែលបានទទួលការតែងតាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ D56/3។ *សូមមើលផងដែរ* ដីកាកំណត់កាលបរិច្ឆេទជាថ្មីពាក់ព័ន្ធនឹងសំណើសុំតែងតាំងសហមេធាវីដែលបានទទួលការតែងតាំង, ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារ D56/4។

ជំហររបស់ខ្លួនទេ[7]។ ដោយសារបែបបទការងារនៅ អ.វ.ត.ក អនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចបំពេញការងារដោយឯករាជ្យពីសមភាគីជាតិ ឬទោះមានការជំទាស់ពីសមភាគីជាតិក៏ដោយនោះ ទើបសហមេធាវីសូមធ្វើការឆ្លើយតបដូចខាងក្រោម។ សហមេធាវីមានរយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃទទួលដំណឹងពីសេចក្ដីសន្និដ្ឋានបន្ថែម ដើម្បីដាក់សារណាឆ្លើយតបមួយ។ ដោយសារការជូនដំណឹងត្រូវបានធ្វើឡើងនៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣ និង ដោយសារយើងខ្ញុំប្រើប្រាស់វិធីសាស្ត្រក្នុងការគណនាដូចសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley យកមកប្រើដែរពោលគឺចាប់ផ្ដើមរាប់មួយថ្ងៃបន្ទាប់ពីថ្ងៃទទួលដំណឹងនោះ (មិនរាប់ថ្ងៃទទួលដំណឹងទេ) កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់សារណានេះគឺថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ហេតុនេះសារណានេះបានដាក់ទាន់ពេលកំណត់។ សហមេធាវីសូមលើកឡើងថា សេចក្ដីសន្និដ្ឋានបន្ថែមដែលបានដាក់ និងជំនួសសំណើ គួរតែត្រូវបានបដិសេធចោល។

## I. កំណត់សម្គាល់បឋម

1. នៅក្នុងសេចក្ដីសន្និដ្ឋានបន្ថែមរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងនូវទឡ្ហីករណ៍មួយបែបប្រលោមលោក ដែលចេញហួសពីវិសាលភាពនៃសេចក្ដីសម្រេចលើកទី២ និង ដីកាកំណត់កាលបរិច្ឆេទជាថ្មី ជាទឡ្ហីករណ៍មួយដែលដាក់បន្ថែម និងមិនពាក់ព័ន្ធនឹងទឡ្ហីករណ៍នានាដែលបានលើកឡើងដើម្បីគាំទ្រដល់សំណើសុំកំណត់កាលបរិច្ឆេទជាថ្មីរបស់ខ្លួន[8]។ ទោះបីសំណើនោះមានទឡ្ហីករណ៍មួយពេញលេញ ពោលគឺអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបាន[9] ក៏ដោយ ក៏សេចក្ដីសន្និដ្ឋានបន្ថែមបានបញ្ចូលទឡ្ហីករណ៍បន្ថែមមួយគឺ

---

[7] ទាំងសេចក្ដីសម្រេច និងដីកានានាដែលពាក់ព័ន្ធនឹងបញ្ហាទំនាស់ផលប្រយោជន៍ដែលបានលើកឡើងដោយ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ពុំមានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេតជាតិលោកចៅក្រម យូ ប៊ុនឡេង ទេ។ ពុំមានកំណត់ហេតុបង្ហាញថា តើលោកចៅក្រម យូ ប៊ុនឡេង បានបញ្ចេញមតិយោបល់ទៅលើបញ្ហានេះជាមួយសមភាគីគាត់គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិលោកចៅក្រម Mark Harmon ឬយ៉ាងណាទេ។

[8] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដើម្បីកំណត់កាលបរិច្ឆេទជាថ្មីក្នុងការដាក់សេចក្ដីសន្និដ្ឋាន ("សំណើសុំកំណត់កាលបរិច្ឆេទជាថ្មី"), ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣, ឯកសារ D56/4/3។

[9] ចំណងជើងរបស់សំណើ (ក៏ដូះបញ្ចាំងនៅក្នុងខ្លឹមសារដែរ) កត់សម្គាល់ពីពាក្យថា "Basis" ("មូលដ្ឋាន") មានន័យជាឯកវចនៈ ឬមួយ ផ្ទុយពីពាក្យថា "Bases" ជាពហុវចនៈ ឬច្រើន។ ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងនូវ

"ការបាត់បង់ទំនុកចិត្តពីសាធារណជនទៅលើ អ.វ.ត.ក និង កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"[10]។ ទោះបីសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មានសេរីភាពក្នុងការលើកឡើងនូវបញ្ហាគតិយុត្តិនានាដែលគាត់គិតថាសមរម្យនៅក្នុងសំណើរបស់ខ្លួន ដែលសុំឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ("ក.ស.ចៈស") បដិសេធការតែងតាំងរបស់អង្គភាពគាំពារការការពារក្តី ("DSS") ចំពោះសហមេធាវីដើម្បីធ្វើជាតំណាងលោក មាស មុត ក្នុងសំណុំរឿង ០០៣ ប្រសិនបើទឡ្ហីករណ៍មួយហួសឆ្ងាយពីវិសាលភាពនៃដីកាមួយនោះ ការអនុវត្តន៍ជាធម្មតា និងតាមក្រមសីលធម៌វិជ្ជាជីវៈគឺអាចឲ្យភាគីសុំការអនុញ្ញាតក្នុងការលើកឡើងទឡ្ហីករណ៍បន្ថែមបាន។ ទោះបីក្នុងករណីដែលសហមេធាវីមានឱកាសក្នុងការឆ្លើយតបក៏ដោយ ក៏ទង្វើបែបនេះបង្ហាញពីចម្ងល់ទៅលើភាពជាក់ស្តែងនៃសំណើសុំកំណត់កាលបរិច្ឆេទជាថ្មីរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley។ ផ្នែកមួយនៃសេចក្តីសន្និដ្ឋានបន្ថែមក៏ជាចម្លើយតបទៅនឹងសារណាតបរបស់សហមេធាវីដែរ[11]។ នេះមិនមែនជាគោលបំណងមួយ ក្នុងចំណោមគោលបំណងនានាដើម្បីឲ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ធ្វើការស្នើសុំដាក់សេចក្តីសន្និដ្ឋានបន្ថែមទេ។ ការយកដំណើរការងារមកលេងសើចមិនគួរអនុញ្ញាតឲ្យមានទេ ទោះបីសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ជាអ្នកប្រព្រឹត្តក៏ដោយ។

## II. ទឡ្ហីករណ៍

2. ទឡ្ហីករណ៍នៅក្នុងសារណាឆ្លើយតបបន្ថែមនេះធ្វើឡើងទៅតាមសេចក្តីសន្និដ្ឋានបន្ថែម គឺមួយកថាខណ្ឌម្តងៗ ហេតុនេះអាចមានភាពលើសលោះខ្លះមិនអាចចៀសវាងបាននៅក្នុងទឡ្ហីករណ៍នានាដែលនឹងលើកឡើងក្នុងសារណានេះ។ ដើម្បីសង្ខេបឲ្យខ្លី និងដោយសារនៅក្នុងសេចក្តីសន្និដ្ឋានបន្ថែម សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងនូវទឡ្ហីករណ៍ដូចគ្នាទៅនឹងអ្វី

---

សំអាងហេតុ (មូលដ្ឋាន) លើសពីមួយ សម្រាប់បដិសេធការតែងតាំងសហមេធាវីនោះ គាត់គួរតែប្រើប្រាស់ឲ្យត្រឹមត្រូវតាមក្បួនវេយ្យាករណ៍គឺនាមពហុវចនៈ "Bases"។

[10] សេចក្តីសន្និដ្ឋានបន្ថែម, កថាខណ្ឌ ៤, ៧០ ដល់ ៧៧។ សំណើមិនបានយោងទៅដល់ការប៉ះពាល់ដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះទេ តែនៅក្នុងបរិបទមួយដោយឡែក។ *សូមមើល* សំណើ, កថាខណ្ឌ ៥២ និង ៥៣; លិខិតសុំការអនុញ្ញាតរបស់សហមេធាវីស្នើសុំបន្ថែមចំនួនទំព័រដែលបានកំណត់ និងសេចក្តីសន្និដ្ឋានរបស់សហមេធាវីទៅលើទំនាស់ផលប្រយោជន៍ដែលអាចកើតមានក្នុងការតំណាងលោក មាស មុត ក្នុងសំណុំរឿង ០០៣, ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ ("សារណាឆ្លើយតប"), ឯកសារ D56/4/1, កថាខណ្ឌ ៤២ ដល់ ៤៤។

[11] *សូមមើលឧទាហរណ៍,* សេចក្តីសន្និដ្ឋានបន្ថែម, កថាខណ្ឌ ៣៥ ដល់ ៤៤។

ដែលមាននៅក្នុងសំណើនោះ សហមេធាវីសូមយោងទៅដល់ទឡ្ហីករណ៍អង្គច្បាប់ និងអង្គហេតុទាំងអស់ដែលបានលើកឡើងនៅក្នុងសារណាតបរបស់ខ្លួនទៅនឹងសំណើនោះ។ គួរចាត់ទុកសារណាឆ្លើយតបបន្ថែមនោះថាភ្ជាប់ជាមួយសារណាឆ្លើយតប ធ្វើជាការឆ្លើយតបរួមមួយ។

## ក. សារណាឆ្លើយតបទៅនឹងច្បាប់ជាធរមាន

3. ផ្នែកច្បាប់ជាធរមាននៃសេចក្តីសន្និដ្ឋានបន្ថែមគឺជាការលាយចម្រុះគ្នារវាងច្បាប់ និងទឡ្ហីករណ៍។ ដោយបានដកស្រង់ចេញពីប្រភពនានាជាច្រើន សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានបង្កើតជាសេចក្តីសន្និដ្ឋានមួយទន់ខ្សោយ និងមិនអាចទទួលយកបានដែលថា មានទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបាន ដែលរារាំងសហមេធាវីមិនឲ្យតំណាងជនណាម្នាក់នៅ អ.វ.ត.ក ទាំងក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤[12] តែជាពិសេសលោក មាស មុត នៅក្នុងសំណុំរឿង ០០៣ តែម្តង។ ទោះបីច្បាប់មួយចំនួនដែលបានលើកឡើងអាចជាព័ត៌មានក៏ដោយ តែច្បាប់នោះអាចយកមកអនុវត្តបានតិចតួចណាស់ចំពោះស្ថានភាពអង្គហេតុបច្ចុប្បន្ន ឬចងកាតព្វកិច្ចដល់ អ.វ.ត.ក បាននោះ។ ដោយមានគំនិតជាទ្រឹស្តី និងអរូបិយនោះ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងថា សហមេធាវី*មានចេតនា* ឬ*ត្រូវតែ* រំលោភលើកាតព្វកិច្ចរក្សាការសម្ងាត់ដែលមានជាមួយលោក អៀង សារី ប្រសិនបើពួកគេត្រូវបានអនុញ្ញាតឲ្យតំណាងលោក មាស មុត នោះ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ធ្វើបែបនេះដោយប្រឌិតឡើងនូវទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ និងសហឧក្រិដ្ឋកម្ម ("JCE")[13]។ ដូចដែលនឹងលើកឡើងជាទឡ្ហីករណ៍យ៉ាងពេញលេញខាងក្រោម សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ពុំបានផ្តល់ភស្តុតាងទេ គ្រាន់តែជាការលាយចម្រុះគ្នារវាងទឡ្ហីករណ៍នានានៅក្នុងផ្ទៃសាច់រឿងទាំងមូលតែប៉ុណ្ណោះ។ គាត់សំអាងទៅលើការប៉ាន់ស្មាន សំដីបញ្ចើតបញ្ចៀង និងប្រភពនានាដែលមិនពាក់ព័ន្ធ (ដូចជាគេហទំព័រ និង សម្រង់អត្ថបទសារព័ត៌មានរបស់មេធាវីការពារក្តី អៀង សារី) ក្នុងគោលបំណងច្របូកច្របល់ដើម្បី*បំពុលបរិយាកាស*។

### ១. កាតព្វកិច្ចរបស់មេធាវីការពារក្តីចំពោះកូនក្តីបច្ចុប្បន្ន និងពីមុន/ដែលបានស្លាប់

---

[12] ទោះបីមិនបានធ្វើឡើងដោយផ្ទាល់ ក៏សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងនូវទឡ្ហីករណ៍នេះដោយប្រយោលនៅក្នុង សេចក្តីសន្និដ្ឋានបន្ថែម, កថាខណ្ឌ ៧០។

[13] សេចក្តីសន្និដ្ឋានបន្ថែម, កថាខណ្ឌ ៥៧ ដល់ ៦២។

4. សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley គ្រាន់តែលើកឡើងជាទឡ្ហីករណ៍សាជាថ្មីពីកថាខណ្ឌ ៧ ដល់ ១៨ នៃសេចក្តីសន្និដ្ឋានបន្ថែម (ទោះបីមានឯកសារសំអាងបន្ថែមក៏ដោយ) នូវអ្វីដែលគាត់បានបង្ហាញរួចមកហើយនៅក្នុងសំណើពីកថាខណ្ឌ ១៦ ដល់ ១៨ និង ពីកថាខណ្ឌ ២០ ដល់ ២២។ នៅពេលពិចារណាទៅលើទឡ្ហីករណ៍ជារួមដែលសហមេធាវីបានដាក់នៅក្នុងសារណាតបនោះ មានការយល់ស្របគួរទទួលយកបាន នូវអ្វីជាកាតព្វកិច្ចដែលមេធាវីមានចំពោះកូនក្តីរបស់ខ្លួន[14]។

5. កថាខណ្ឌ ៧៖ ពុំមានការជំទាស់ទេដែលថា មេធាវីមានកាតព្វកិច្ចផ្តល់ទំនុកចិត្តដល់កូនក្តីរបស់ខ្លួន។

6. កថាខណ្ឌ ៨ ដល់ ១២៖ ពុំមានការជំទាស់ទេដែលថា កាតព្វកិច្ចផ្តល់ទំនុកចិត្តដែលរួមមានការរក្សាការសម្ងាត់នោះ មានវិសាលភាពបន្ទាប់ពីកូនក្តីស្លាប់ទៅហើយក្តី។

7. កថាខណ្ឌ ១៣៖ ពុំមានការជំទាស់ទេដែលថា កាតព្វកិច្ចរក្សាការសម្ងាត់អាច តែ *មិនចាំបាច់ថានឹងត្រូវ* មានឥទ្ធិពលទៅលើលទ្ធភាពរបស់មេធាវីក្នុងការអនុវត្តតាមកាតព្វកិច្ចផ្តល់ទំនុកចិត្តដល់កូនក្តីពីមុនរបស់ខ្លួន និងបច្ចុប្បន្នទេ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ពុំបានផ្តល់នូវឯកសារសំអាងទេ ដោយសម្រេចថា នៅគ្រប់កាលៈទេសៈទាំងអស់ ទោះបីអង្គហេតុ ឬទ្រឹស្តីពីនៃសំណុំរឿង និងការការពារក្តីអាចជាអ្វីក៏ដោយ ក៏មានគោលការណ៍នីត្យានុកូលភាពសាកលមួយដែលថាការសម្ងាត់ *ត្រូវ*បានគេបំពាន ដើម្បីផ្តល់នូវការតំណាងតាមផ្លូវច្បាប់បានល្អ និងខ្លាំងក្លា ចំពោះកូនក្តីបច្ចុប្បន្ន ដែលត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងទៅនឹងទង្វើ ឬសកម្មភាពនានាដែលកូនក្តីពីមុនក៏ត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងដែរនោះ។

8. សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley យល់ដឹងពីបទពិសោធន៍របស់គាត់ក្នុងនាមជារដ្ឋអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) (ដូចសហចៅក្រមស៊ើបអង្កេតអន្តរជាតិលោកចៅក្រម Mark Harmon ដែរ) គឺថា មេធាវីការពារក្តីត្រូវបានតែងតាំងឲ្យកាន់រឿងក្តីជាច្រើនដូចជារឿងក្តីនានានៅ Srebrenica ជាដើម[15] ដែលកូនក្តីពីមុន និងបច្ចុប្បន្ន

---

[14] *សូមមើលឧទាហរណ៍,* សារណាឆ្លើយតប, កថាខណ្ឌ ៤។

[15] ប្រវត្តិរូបរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley នៅលើគេហទំព័រ Wikipedia អះអាងថា ក្នុងចំណោមចំណុចផ្សេងៗ គាត់ “ត្រូវបានចាត់ឲ្យបំពេញការងារនៅឆ្នាំ ១៩៩៥ ជារដ្ឋអាជ្ញាផ្នែកយោធា ដោយការិយាល័យកិច្ចការបរទេស និងបណ្តារដ្ឋសហធន និង ក្រសួងការពារជាតិ ទៅបំពេញការងារនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICTY") គាត់បានស៊ើបអង្កេត និងចោទប្រកាន់រឿងក្តី ... រដ្ឋអាជ្ញា តទល់នឹង ឧត្តមសេនីយ៍ Radoslav Krstić (Srebrenica) និង ... នៅឆ្នាំ ២០០១ គាត់ត្រូវ

របស់ពួកគេត្រូវបានចោទប្រកាន់ថាមានការពាក់ព័ន្ធនឹងព្រឹត្តិដូចគ្នា ហើយដែលសហឧក្រិដ្ឋកម្មរួម និង/ឬ ការទទួលខុសត្រូវរបស់មេបញ្ជាការ/ថ្នាក់លើ ត្រូវបានចោទប្រកាន់ជាទម្រង់នៃការទទួលខុសត្រូវ[16]។ ពុំមែនជាការគួរឲ្យភ្ញាក់ផ្អើលទេដែលថា សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មិនបាននិយាយដល់រឿងក្តីនានានៅតុលាការ ICTY ទេ កុំថាឡើយដល់ទៅលើកឡើងពីរឿងក្តីទាំងនេះនៅក្នុងទឡ្ហីករណ៍របស់ខ្លួននោះ។ ប្រការគួរឲ្យកត់សម្គាល់នោះគឺថា សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ក៏មិនបានលើកឡើងពីការចូលរួមរបស់គាត់នៅតុលាការ ICTY ក្នុង*រឿងក្តី Gotovina* រួមទាំងការចូលរួមនៃសហសេវិកគាត់ជាអតីតរដ្ឋអាជ្ញានៅតុលាការ ICTY ដូចដែលនឹងលើកឡើងជាទឡ្ហីករណ៍ពេញលេញខាងក្រោម។

9. កាតព្វកិច្ចនៃការរក្សាការសម្ងាត់ ក៏ដូចជាកាតព្វកិច្ចផ្តល់ទំនុកចិត្តផ្សេងៗទៀតដែរ គឺអនុវត្តចំពោះអតីតរដ្ឋអាជ្ញានានាដែលក្រោយមកក្លាយជាមេធាវីការពារក្តីជនជាប់ចោទក្នុងរឿងក្តី ដែលពួកគេបានចូលរួមដោយផ្ទាល់ ឬដោយប្រយោល និងការដឹងពីកិច្ចការផ្ទៃក្នុង កាលនៅជារដ្ឋអាជ្ញាដែរ[17]។ និយាយម្យ៉ាងទៀត អតីតរដ្ឋអាជ្ញានៃតុលាការ ICTY មានកាតព្វកិច្ចផ្តល់ទំនុកចិត្តដល់អតីត

---

បានតែងតាំងជាមេធាវីសវនាការជាន់ខ្ពស់ ... ហើយនៅក្នុងសមត្ថភាពនោះ គាត់ទទួលខុសត្រូវរឿងក្តីប្រឆាំងនឹងឧត្តមសេនីយ៍ Ratko Mladic"។ *សូមមើល* គេហទំព័រ Wikipedia ដែលអាចរកមើលបាននៅ http://en.wikipedia.org/wiki/Andrew_Cayley។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិលោកចៅក្រម Mark Harmon ក៏បានចូលរួមចំណែកក្នុងក្រុមសវនាការក្នុងសំណុំរឿង *រដ្ឋអាជ្ញា តទល់នឹង Krstić* (Srebrenica) ហើយគាត់បានធ្វើការក្នុងសមត្ថភាពនានាជាច្រើនក្នុងរឿងក្តីផ្សេងៗទៀតនៅ Srebrenica។ ហេតុនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិលោកចៅក្រម Harmon បានដឹងយ៉ាងច្បាស់នូវអង្គហេតុនានា និងស្គាល់ច្បាស់នូវមេធាវីការពារក្តីដែលបានតំណាងជនជាប់ចោទជាច្រើននៅក្នុងរឿងក្តីផ្សេងៗនៅ Srebrenica រួមទាំងរឿងក្តីផ្សេងៗទៀតនៅតុលាការ ICTY។

[16] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ២១។

[17] វាជាការពិតដែលគេដឹងជាទូទៅនៅតុលាការ ICTY ថា មុនពេលចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ រដ្ឋអាជ្ញាត្រូវបានអញ្ជើញឲ្យចូលរួមក្នុងក្រុមពិនិត្យឡើងវិញ។ ហេតុនេះ រដ្ឋអាជ្ញាដែលមិនអាចចូលរួមក្នុងក្រុមអយ្យការក្នុងរឿងក្តីជាក់លាក់ណាមួយ នឹងចូលរួម និងផ្តល់ព័ត៌មានផ្ទៃក្នុងដែលអាចនឹងមិនត្រូវបានលាតត្រដាងទៅឲ្យក្រុមមេធាវីការពារក្តី ឬសូម្បីតែអង្គជំនុំជម្រះ (*សូមមើល ឧទាហរណ៍* មាត្រា ១៨(២) នៃលក្ខន្តិកៈតុលាការ ICTY និង វិធាន ៣៩, ៥៩*ស្ទួន* និងជាពិសេសវិធាន ៧០ នៃវិធានស្តីពីនីតិវិធីនិងភស្តុតាងនៃតុលាការ ICTY) យុទ្ធសាស្ត្រ និងរបាយការណ៍វិភាគដែលចាត់ទុកជាសម្ងាត់ សមិទ្ធផលការងារ ។ល។ *សូមមើល ឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić*, សំណុំរឿងលេខ IT-02-60 សេចក្តីសម្រេចលើសំណើរបស់ស៊ុំ Vidoje Blagojević បង្ខំឲ្យអយ្យការលាតត្រដាងនូវកំណត់ត្រារបស់ខ្លួនពីការពិភាក្សាលើសំណើបន្ទាន់ ជាមួយជនជាប់ចោទ Nikolic និង សំណើសុំឲ្យមានសវនាការសាធារណៈឆាប់រហ័ស, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៣។

និយោជក/កូនក្តីរបស់ខ្លួន ការិយាល័យអយ្យការនៃតុលាការ ICTY ("ICTY-OTP")។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដឹងយ៉ាងច្បាស់ពីរឿងនេះ ដោយសារគាត់មានទំនាក់ទំនងជាយូរជាមួយនឹង ICTY-OTP និងឧបសគ្គនានាដែល OTP បានជួបប្រទះ ក្នុងការប៉ុនប៉ងរារាំងអតីតរដ្ឋអាជ្ញាមិនឲ្យគេតែងតាំងជាមេធាវីការពារក្តីលើរឿងក្តីនានានៅតុលាការ ICTY[18]។

10. សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ខ្លួនឯងផ្ទាល់ធ្លាប់ជាមេធាវីការពារក្តីក្នុង*រឿងក្តី Gotovina*[19] ដែលសហការីរបស់គាត់ពីរនាក់ទៀតដែលមកពី ICTY-OTP ជាមួយគ្នា (ដូចសហចៅក្រមស៊ើបអង្កេតអន្តរជាតិលោកចៅក្រម Mark Harmon ដែរ) ក៏ជាមេធាវីការពារក្តីដែរ ជាថៃ្ងដន្យ មេធាវីការពារក្តីទាំងនេះក៏បានបង្កើតគេហទំព័រមួយក្នុងនាមកូនក្តីរបស់ខ្លួនគឺឧត្តមសេនីយ៍ Ante Gotovina[20]។

11. *រឿងក្តី Gotovina* ជាឧទាហរណ៍ពិសេសមួយ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley លោក Gregory Kehoe និង លោក Payam Akhavan ត្រូវបានជនជាប់ចោទជ្រើសរើសជាមេធាវីការពារក្តីឯកជន ទោះបីអតីតសមាជិកជាន់ខ្ពស់នៃ ICTY-OTP ទាំងនេះ បានដឹងដោយផ្ទាល់ និង/ឬ ដោយប្រយោល និង/ឬ បានចូលរួមក្នុងរឿងក្តីពាក់ព័ន្ធដែលភ្ជាប់ទៅនឹងព្រឹត្តិការណ៍នានានៅក្នុង *រឿងក្តី Gotovina* ក៏ដោយ[21]។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley អាចគ្រាន់តែបានដើរតួនាទីទី២ ឬទី៣[22] តែគាត់មិនអាចត្រូវបានផ្តាច់ចេញពីការបំពានលើការរក្សាការ

---

[18] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ២២ ដោយពិភាក្សាពី *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និង Kubura*។

[19] សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានបំពេញការងារខាងក្រុមមេធាវីការពារក្តីដល់ជនជាប់ចោទ Ivan Čermak។

[20] *សូមមើល* គេហទំព័រ៖ www.antegotovina.com។

[21] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ១៨។

[22] ប្រវត្តិរូបរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley នៅលើគេហទំព័រ Wikipedia អះអាងថា បន្ទាប់ពីបានចាកចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley "បានទទួលការណែនាំភ្លាមពីលោក Ivan Čermak ក្នុងការការពារក្តីគាត់"។ នៅក្នុងប្រវត្តិរូបរបស់ខ្លួនសម្រាប់អង្គជំនុំជម្រះ Doughty Street ដែលគាត់ចុះឈ្មោះជាមេធាវីរងនោះ ព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ទំនងជាដើរតួនាទីបន្ទាប់បន្សំនៅក្នុងរឿងក្តីនោះ ទោះបីគាត់ចង់បានកិត្តិយសចំពោះលទ្ធផលដែលនាំឲ្យលើកលែងការចោទប្រកាន់ដល់ជនជាប់ចោទក៏ដោយ ទោះបីគាត់បានបោះបង់ចោលក្រុមនោះនៅពាក់កណ្តាលពេលសវនាការដើម្បីមកទទួលតំណែងបច្ចុប្បន្នក៏ដោយ។ សូមមើលគេហទំព័រនៃអង្គជំនុំជម្រះ Doughty Street *ដែលអាចនៅបាននៅ៖* http://www.doughtystreet.co.uk/barristers/associate_tenants/tenant_details.cfm?iTennantID=346។

សម្ងាត់ ឬ កាតព្វកិច្ចផ្តល់ទំនុកចិត្តផ្សេងៗទៀតរបស់គាត់ទេ។ លោក Kehoe បានដើរតួនាទីសំខាន់ក្នុងចំណោមសហមេធាវីទាំងអស់ ទោះបីសម្រាប់ជាចេតនា ឬគោលបំណងទាំងអស់ក៏ដោយ ក៏គាត់មានតួនាទីជាមេធាវីនាំមុខក្នុងសវនាការក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការ។ *រឿងក្តី Gotovina* បង្ហាញពីភាពមិនសមហេតុសមផល និងការលាក់ពុតនៃអំណះអំណាងបែបទូទៅរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley៖ ថា វាជាការសន្និដ្ឋានដែលធ្វើឲ្យកន្លងផុតទៅដែលថា នៅគ្រប់ករណីទាំងអស់ ភាពសម្ងាត់របស់កូនក្តីពីមុន*ពីស្ប្ត្រូវ*បានបំពានសម្រាប់មេធាវីការពារក្តី ដើម្បីតំណាងកូនក្តីបច្ចុប្បន្នឲ្យបានត្រឹមត្រូវ និងខ្លាំងក្លា។

12. កថាខណ្ឌ ១៤ ដល់ ១៨៖ កថាខណ្ឌទាំងនេះគ្រាន់តែជាការលើកឡើងដដែលពីកថាខណ្ឌ ៨ ប៉ុណ្ណោះ។ ការយោងទៅដល់ "សេចក្តីថ្លៃថ្នូរ កិត្តិយស កិត្តិនាម និងភាពឯកជន" នៅក្នុងកថាខណ្ឌ ១៦ និងរឿងក្តីយុត្តិសាស្ត្រដែលមានក្នុងកថាខណ្ឌ ១៧ ដល់ ១៨ ក៏មិនចាំបាច់៖ *សេចក្តីថ្លៃថ្នូរ កិត្តិយស កិត្តិនាម* និង*ភាពឯកជន* គឺជាផ្នែកមួយនៃកាតព្វកិច្ចផ្តល់ទំនុកចិត្តរបស់មេធាវីការពារក្តី ដូចបានកត់សម្គាល់ក្នុងកថាខណ្ឌ ៧។

## ២. កាតព្វកិច្ចរបស់មេធាវីការពារក្តីក្នុងការបញ្ចៀសទំនាស់ផលប្រយោជន៍

13. កថាខណ្ឌ ១៩៖ ពុំមានការជំទាស់ទេដែលថា មេធាវីនៅចំពោះមុខ អ.វ.ត.ក ឬនៅតុលាការផ្សេងៗទៀតដែលមានបញ្ហាបែបនោះ ទោះជានៅថ្នាក់ជាតិក្តី ឬអន្តរជាតិក្តី មានកាតព្វកិច្ចបញ្ចៀសទំនាស់ផលប្រយោជន៍ដោយការដកខ្លួនចេញពីរឿងក្តី ឬការព្រមព្រៀង។ ទោះបីសហមេធាវីជឿថា ទំនាស់ផលប្រយោជន៍ពុំកើតមានចំពោះការតំណាងលោក មាស មុត ដោយសារធ្លាប់តំណាងលោក អៀង សារី ក៏ដោយ តែដោយមានការប្រុងប្រយ័ត្ន និងបន្ទាប់ពីបានពិគ្រោះយោបល់យ៉ាងយកចិត្តទុកដាក់ និងល្អិតល្អន់ជាមួយកូនក្តីទាំងពីរនាក់រួចមក សហមេធាវីក៏បានទទួលលិខិតលះបង់សិទ្ធិដែរ[23]។

14. កថាខណ្ឌ ២០ ដល់ ២៣៖ ពុំមានការជំទាស់ទេដែលថា មេធាវីគួរប្រើសន្និច្ឆ័យសមហេតុសមផលក្នុងការវិនិច្ឆ័យថាតើមានទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបាន ដោយតម្រូវឲ្យដកខ្លួនចេញពីរឿងក្តីមួយ។ ជាការសន្មតគឺថា សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley និង

[23] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ៦, ១០, ២៣, ២៥, ៣៥។

អតីតសហការីរបស់គាត់នៅ OTP ដោយបានប្រើសន្និដ្ឋានសមហេតុសមផល អាចសន្និដ្ឋានបានថា ពួកគេអាចអនុវត្តតាមកាតព្វកិច្ចផ្តល់ទំនុកចិត្តរបស់ខ្លួនចំពោះអតីតមេធាវី/កូនក្តី ICTY-OTP និងកូនក្តីបន្តបន្ទាប់នៅក្នុង*រឿងក្តី Gotovina* បាន[24]។ ករណីដូចគ្នាក៏ជាការពិតដែរសម្រាប់មេធាវីការពារក្តីទាំងអស់ចំពោះកាតព្វកិច្ចស្រដៀងគ្នា ដូចជាបណ្តាមេធាវីការពារក្តីក្នុងរឿងក្តីនានានៅ Srebrenica ជាដើម[25]។

15. ដូចបានកត់សម្គាល់ក្នុងកថាខណ្ឌ*ខាងលើ*រួចមកហើយគឺថា ពុំមានគោលការណ៍សាកលដែលថាទំនាស់ផលប្រយោជន៍ពិតជានាំឲ្យដកគុណវុឌ្ឍិជាមេធាវីក្នុងករណីនានា ដូចករណីបច្ចុប្បន្ននេះទេ។ ក្នុងកថាខណ្ឌ ២៣ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដកស្រង់រឿងក្តីនានាពីសហរដ្ឋអាមេរិក។ ទោះបីរឿងក្តីទាំងនេះគួរឲ្យចាប់អារម្មណ៍ក៏ដោយ តែរឿងក្តីទាំងនោះមិនមែនគ្រប់គ្រងនៅ អ.វ.ត.ក ទេ។ មិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេដែលថា សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានកាត់បន្ថយតម្លៃ ឬគុណសម្បត្តិនៃរឿងក្តីនានានៅតុលាការ ICTY ដូចជា*រឿងក្តី Hadžihasanović* ជាដើម ដែលមិនគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់គាត់[26]។ នៅក្នុង*រឿងក្តី Hadžihasanović* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY តម្រូវឲ្យបង្ហាញភស្តុតាង "ពិត"។ ការគិតស្មាន និងការប៉ាន់ស្មានមិនទាន់គ្រប់គ្រាន់ទេ។ នៅក្នុងករណីនេះ ដូចក្នុង*រឿងក្តី Hadžihasanović* ដែរ ការទទួលខុសត្រូវគឺស្ថិតនៅលើសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ក្នុងបង្ហាញពីភស្តុតាងដែលអាចទទួលយកបានថា មានទំនាស់ផលប្រយោជន៍ "ពិត" មែន។ ក្រៅពីការអះអាងផ្ទុយពីអង្គហេតុនៅតុលាការថ្នាក់ជាតិ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មិនបានបង្ហាញភស្តុតាង "ពិត" នៃទំនាស់ផលប្រយោជន៍ដែលមិនអាចសម្របសម្រួលបានទេ។

---

[24] តាមតែអ្វីដែលសហមេធាវីបានដឹងគឺថា ICTY-OTP មិនដែលដាក់សំណើណាមួយទេ យ៉ាងហោចណាស់ជាសាធារណៈ ដើម្បីដក ព្រះរាជអាជ្ញាអន្តរជាតិលោក Cayley លោក Kehoe ឬ លោក Akhavan ចេញពីរឿងក្តី ដោយសារតែទំនាស់ផលប្រយោជន៍មិនអាចសម្របសម្រួលបាននោះទេ។

[25] ជាថ្មីម្តងទៀត ពុំមានកំណត់ហេតុណាមួយដែលថា សេចក្តីសន្និដ្ឋានផ្លូវការដែលត្រូវធ្វើពាក់ព័ន្ធនឹងបញ្ហាទំនាស់ផលប្រយោជន៍មិនអាចសម្របសម្រួលបានជាមួយមេធាវីការពារក្តីដែលត្រូវបានតែងតាំង និងបានចូលរួមក្នុងរឿងក្តីនានានៅ Srebrenica ឬ*រឿងក្តី Mladić* ដែលបញ្ចូលក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាព្រឹត្តិការណ៍នានានៅ Srebrenica ដែលជនជាប់ចោទ Ratko Mladić ស្ថិតក្នុងតួនាទីនៃការទទួលខុសត្រូវ គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម និង ក្រោមការទទួលខុសត្រូវរបស់ថ្នាក់លើ/មេបញ្ជាការ ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត។

[26] សេចក្តីសន្និដ្ឋានបន្ថែម, កថាខណ្ឌ ២២។

16. សហមេធាវីបានទទួលស្គាល់ទាំងស្រុងពីកាតព្វកិច្ចផ្តល់ទំនុកចិត្តរបស់ខ្លួនចំពោះលោក អៀង សារី និងលោក មាស មុត មានរួមការ ការរក្សាសម្ងាត់ ភក្តីភាព ការបំពេញការងារយ៉ាងយកចិត្តទុកដាក់ ភាពស្មោះត្រង់ និងការលាតត្រដាងការពិត។ សហមេធាវីពុំដែលបានលើកឡើងនូវទឡ្ហីករណ៍នានាតាមផ្លូវច្បាប់ ឬធ្វើការអះអាងលើអង្គហេតុដែលធ្វើឲ្យប៉ះពាល់ដល់ភារកិច្ចរក្សាការសម្ងាត់របស់លោក អៀង សារី ឬ លោក មាស មុត ទេ។ ស្រដៀងគ្នាដែរ សហមេធាវីមិនមែនបានអះអាងថា ភារកិច្ចរក្សាការសម្ងាត់របស់ លោក អៀង សារី ត្រូវបានបញ្ចប់នៅពេលគាត់ស្លាប់នោះទេ។

## ៣. កាលៈទេសៈនានានៅពេលដែលទំនាស់ផលប្រយោជន៍កើតឡើង

17. កថាខណ្ឌ ១៧៖ ពុំមានការជំទាស់ទេដែលថា នៅក្នុងយុត្តាធិការខ្លះ មានវិធានផ្នែកវិជ្ជាជីវៈដែលអំពាវនាវឲ្យមេធាវីត្រូវបញ្ឈប់ពីការធ្វើជាតំណាងកូនក្តី នៅពេលដែលផលប្រយោជន៍របស់កូនក្តីពីមុន និងបច្ចុប្បន្នមានភាពប្រទាំងប្រទើសជាក់ស្តែង។ អ្វីដែលបង្កើតឲ្យមានការផលប្រយោជន៍ប្រទាំងប្រទើសជាក់ស្តែងគឺជាភាពជាក់លាក់ទៅតាមរឿងក្តី/កូនក្តី ដូចបានឆ្លុះបញ្ចាំងក្នុងរឿងក្តីនានានៅ Srebrenica និង *រឿងក្តី Gotovina* ស្រាប់។

18. កថាខណ្ឌ ២៥៖ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដកស្រង់វិធាននានានៅថ្នាក់ជាតិ និង រឿងក្តីយុត្តិសាស្ត្រនៅប្រទេសសិង្ហបុរី ដើម្បីលើកឡើងថា វាជាការដែលអាចប្រមើលជាមុនបានសមរម្យថា ការដឹងពីអង្គហេតុជាក់លាក់នៅពេលធ្វើជាតំណាងមួយពីមុនដែលពាក់ព័ន្ធនឹងបញ្ហាមួយក្នុងការតំណាងកូនក្តីបច្ចុប្បន្ន នឹងទៅជាទំនាស់ផលប្រយោជន៍ដោយស្វ័យប្រវត្តិ និងតម្រូវឲ្យដកខ្លួន ឬដកគុណវុឌ្ឍិដោយស្វ័យប្រវត្តិ។ ការលើកឡើងបែបនេះមិនត្រឹមត្រូវទេ។ មេធាវីអាចទទួលបានអង្គហេតុជាក់លាក់ពីសំណុំរឿង ឬពីសក្ខីកម្មរបស់សាក្សី។ បញ្ហានៅត្រង់ថា តើការដឹងនោះបានមកពីកូនក្តីមុនដែលមេធាវីមិនអាចទទួលបានតាមវិធីផ្សេងទៀតឬទេ និងថាតើការដឹងនេះនឹងត្រូវយកទៅប្រើប្រាស់ដើម្បីជួយកូនក្តីបច្ចុប្បន្ន ដែលធ្វើឲ្យអន្តរាយដល់កូនក្តីមុនឬទេ។ ជាថ្មីម្តងទៀត រឿងក្តីនានានៅ Srebrenica រួមទាំង*រឿងក្តី Gotovina* បានបង្ហាញពីសេចក្តីអះអាងទូទៅរបស់ច្បាប់ដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ទំនងជាលើកឡើងនោះ។ នៅក្នុងកាលៈទេសៈណាក៏ដោយ សហមេធាវីមានសុទ្ធចិត្តក្នុងការអះអាងថា នឹងមិនយកអ្វីដែលពួកខ្លួនបានដឹងពីលោក អៀង សារី មកប្រើប្រាស់ដើម្បីជួយលោក មាស មុត ដែលធ្វើឲ្យអន្តរាយដល់

លោក អៀង សារី វិញទេ។ ស្រដៀងគ្នានេះដែរ សហមេធាវីកាន់តែមានសុទ្ធចិត្តទៅទៀតក្នុងការអះអាងថា នឹងមិនយកអ្វីដែលពួកខ្លួនបានដឹងពីលោក មាស មុត មកប្រើប្រាស់ដើម្បីការពារលោក អៀង សារី ដែលធ្វើឲ្យអន្តរាយដល់លោក មាស មុត វិញទេ។ ការតំណាងទាំងនេះត្រូវបានធ្វើឡើងដោយផ្អែកលើទ្រឹស្តីនានានៃសំណុំរឿងដែលទាំងលោក អៀង សារី និង លោក មាស មុត បានណែនាំឲ្យសហមេធាវីដំណើរការទៅមុន បន្ទាប់ពីបានពិគ្រោះយោបល់ ទទួលយកដំបូន្មាន និងមានការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់។

19. កថាខណ្ឌ ២៦ ដល់ ២៨៖ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មិនបានផ្តល់អ្វីថ្មីដែលមិនធ្លាប់ត្រូវបានយកមកពិភាក្សា ក្រៅតែពីដកស្រង់នូវវិធានស្តីពីវិជ្ជាជីវៈជាច្រើនពីយុត្តាធិការថ្នាក់ជាតិ និងសមាគមច្បាប់ស្ម័គ្រចិត្ត (ដូចជាគណៈមេធាវីអន្តរជាតិ និង គណៈមេធាវីព្រហ្មទណ្ឌអន្តរជាតិ) និងច្បាប់យុត្តិធម៌ថ្នាក់ជាតិតែប៉ុណ្ណោះ។ ដូចដែលសហមេធាវីបានបង្ហាញក្នុងកថាខណ្ឌមុនរួចមកហើយគឺថា ផលប្រយោជន៍របស់លោក អៀង សារី និង និង លោក មាស មុត នឹងមិនត្រូវបានប៉ះពាល់ទេ ហើយគ្មាននរណាម្នាក់ក្នុងចំណោមពួកគេនឹងត្រូវទទួលរងនូវការខូចប្រយោជន៍ទេ ប្រសិនបើការតែងតាំងរបស់អង្គភាពគាំពារការការពារក្តីឲ្យសហមេធាវីតំណាងលោក មាស មុត ត្រូវបានទទួលយកនោះ។ ទោះក្នុងកម្រិតណាក៏ដោយ តែដោយឡែកលោក មាស មុត នឹងបានទទួលប្រយោជន៍ពីការទទួលយកជាទូទៅរបស់សហមេធាវីទៅលើព្រឹត្តិការណ៍ ដែលស្ថិតក្រោមយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក ការដឹងរបស់ពួកគេចំពោះភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលមានក្នុងសំណុំរឿង ០០២ និង ការយល់ដឹងទាំងស្រុងរបស់ពួកគេចំពោះយុត្តិសាស្ត្រ និងនីតិវិធីដែលយកមកអនុវត្តនៅ អ.វ.ត.ក តាមរយៈការធ្វើជាតំណាងលោក អៀង សារី រយៈពេលជាង ៥ ឆ្នាំមកនេះ។ ការពិត ទាំងនេះជាកត្តាដែលធញរើឲ្យអង្គភាពគាំពារការការពារក្តីអនុម័តនូវការតែងតាំងនេះ[27]។

20. កថាខណ្ឌ ២៩៖ សហមេធាវីទទួលស្គាល់ថា ទំនាស់ផលប្រយោជន៍នឹងកើតឡើង នៅពេលមាន "មហន្តរាយពិតប្រាកដ" មួយដល់កូនក្តីបច្ចុប្បន្ន តាមរយៈការធ្វើជាតំណាងកូនក្តីពីមុន។ ទោះជា

---

[27] *សូមមើល* សេចក្តីប្រកាសព័ត៌មាននៅ អ.វ.ត.ក "លោក អាង ឧត្តម និង លោក Michael G. Karnavas បានទទួលការតែងតាំងជាមេធាវីការពារក្តីតំណាងជនសង្ស័យមួយរូបក្នុងសំណុំរឿង ០០៣", ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ *អាចរកបាននៅ៖* http://www.eccc.gov.kh/en/articles/mr-ang-udom-and-mr-michael-g-karnavas-assigned-defence-counsel-represent-suspect-case-003។

យ៉ាងណាក្តី ដូចដែលបានលើកឡើង*ខាងលើ*រួចមកហើយគឺថា ស្ថានភាពនេះគឺជាភាពជាក់លាក់ទៅតាមរឿងក្តី និង ពឹងផ្អែកជាខ្លាំងទៅលើកត្តានានាជាច្រើន រួមទាំងទ្រឹស្តីនៃការការពារក្តីផងដែរ។ ការអះអាងជាសម្មតិកម្មដែលមិនត្រឹមត្រូវ និងបែបរវើរវាយដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley យកមកប្រឌិត ដោយផ្អែកលើការបកស្រាយ*របស់ខ្លួន*ចំពោះព្រឹត្តិការណ៍នានាដែលត្រូវបានចោទប្រកាន់នោះ ពុំមែនជាភស្តុតាងបង្ហាញថាមាន "មហន្តរាយពិតប្រាកដ" នឹងកើតឡើងចំពោះលោក អៀង សារី ឬលោក មាស មុត នោះទេ ប្រសិនបើសហមេធាវីតំណាងលោក មាស មុត ក្នុងសំណុំរឿង ០០៣ នោះ។

21. កថាខណ្ឌ ៣០ ដល់ ៣១៖ ពុំមានការហាមឃាត់មិនឲ្យមានលិខិតលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរស្តីពីទំនាស់ផលប្រយោជន៍ទេ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ដឹងថា លិខិតលះបង់សិទ្ធិ ដូចដែលលោក អៀង សារី និង លោក មាស មុត បង្ហាញជូននោះ ត្រូវបានទទួលយកជាធម្មតានៅតុលាការ ICTY ឬតុលាការអន្តរជាតិផ្សេងៗទៀត[28]។

22. សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ទទួលស្គាល់ថា ពុំមានការហាមឃាត់ជាក់ស្តែងមិនឲ្យមានលិខិតលះបង់សិទ្ធិនៅក្នុងច្បាប់កម្ពុជាទេ។ ជាងនេះទៀត គាត់មិនបានផ្តល់នូវឯកសារសំអាងតាមផ្លូវច្បាប់ដែលចងកាតព្វកិច្ចនៅ អ.វ.ត.ក ដែលចែងថា លិខិតលះបង់សិទ្ធិ ដូចដែលលោក អៀង សារី និង លោក មាស មុត បង្ហាញជូននោះត្រូវបានហាមឃាត់ ឬពុំត្រឹមត្រូវតាមទម្រង់ ឬខ្លឹមសារនោះទេ។ ទោះបី អ.វ.ត.ក ពុំមានកាតព្វកិច្ចត្រូវអនុវត្តច្បាប់បារាំង ឬក្រមសីលធម៌ផ្សេងៗទៀតក៏ដោយ តែតាមរយៈអំណានយ៉ាងយកចិត្តទុកដាក់ទៅលើឯកសារសំអាងតាមផ្លូវច្បាប់នេះ*ពុំបាន*អំពាវនាវឲ្យមានការហាមឃាត់ដាច់ខាតថាមិនឲ្យមានលិខិតលះបង់សិទ្ធិទេ។ ការកំណត់និយមន័យនូវអ្វីដែលហៅថា ទំនាស់ផលប្រយោជន៍ ក្នុងច្បាប់/ក្រមបារាំង ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងក្នុងកថាខណ្ឌ ៣១ នោះស្របជាខ្លាំងទៅនឹងអ្វីដែលធ្លាប់បានយកមកពិភាក្សារួចហើយ ហេតុនេះភាពលើសពីតម្រូវការមិនបានបន្ថែមតម្លៃពិតប្រាកដទេ។ នៅក្នុងកាលៈទេសៈណាក៏ដោយ សហមេធាវី៖ (១) មានសមត្ថភាពពេញលេញ និងមានឆន្ទៈក្នុងការផ្តល់នូវព័ត៌មានពេញលេញ និងត្រឹមត្រូវ និងដំបូន្មានជូនលោក មាស មុត ដោយមិនឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់លោក អៀង សារី ទេ និង (២) ភាពតំណាងរបស់ពួកគេចំពោះ

[28] *សូមមើល* សេចក្តីសន្និដ្ឋានបន្ថែម, កថាខណ្ឌ ៤៨។ *សូមមើលផងដែរ* កថាខណ្ឌ ២៧ *ខាងក្រោម*។

លោក មាស មុត នឹងមិននាំឲ្យពួកគេទទួលយកនូវទ្រឹស្តី ឬយុទ្ធសាស្ត្រផ្សេងពីអ្វីដែលពួកគេនឹងយកមកអនុវត្ត ប្រសិនបើពួកគេមិនបានតំណាងលោក អៀង សារី នោះទេ។ សេចក្តីអះអាងផ្ទុយដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានលើកឡើងពុំមានមូលដ្ឋានត្រឹមត្រូវ និងគ្រាន់តែជាការប្រឌិតប៉ុណ្ណោះ។

## ៤. សិទ្ធិរបស់កូនក្តីក្នុងការលះបង់សិទ្ធិក្នុងករណីមានទំនាស់ផលប្រយោជន៍

23. កថាខណ្ឌ ៣២ ដល់ ៤៤៖ ពុំមានការជំទាស់ទេដែលថា លិខិតលះបង់សិទ្ធិរបស់កូនក្តីត្រូវបានកំរិតទៅតាមកាលៈទេសៈ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មិនបានផ្តល់ភស្តុតាង*ពិតប្រាកដ* នៅក្នុងកថាខណ្ឌទាំងនេះទេ ដែលជាការលាយចម្រុះគ្នារវាងច្បាប់ និងទឡ្ហីករណ៍ (ចម្លើយតប) ដែលបានបង្ហាញថា លិខិតលះបង់សិទ្ធិដែលបានទទួលក្នុងរឿងក្តីនេះមិនត្រូវបានទទួលដោយត្រឹមត្រូវទេ ថាកូនក្តីដែលពាក់ព័ន្ធមិនបានទទួលព័ត៌មាននិងការផ្តល់ដំបូន្មានបានពេញលេញទេ ឬថា ពួកគេមិនបានដឹងពីលក្ខណៈនៃព្រឹត្តិការណ៍ដែលពួកគេត្រូវបានជំនុំជម្រះ ឬស៊ើបអង្កេតទេ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley មានសិទ្ធិលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់ខ្លួនបាន តែមិនមានសិទ្ធិលើកឡើងនូវអង្គហេតុផ្ទាល់ខ្លួនទេ។

24. ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានផ្តេកផ្តួលទៅតាមការប៉ាន់ស្មាន និងពាក្យបញ្ជិតបញ្ជៀត ដោយប្រៀបប្រដូចមិនត្រឹមត្រូវនូវរឿងក្តីបច្ចុប្បន្នទៅនឹងអង្គហេតុ និងកាលៈទេសៈនានាក្នុង*រឿងក្តី Mejakić* ខណៈដែលបន្តនិយាយយោងទៅដល់*រឿងក្តី Prlić* (ដូចជារឿងក្តីនេះគួរឲ្យជឿជាក់បានជាង ដោយសារលោក Karnavas ធ្លាប់តំណាង វេជ្ជបណ្ឌិត Prlić)។ ទោះបីសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley លើកឡើងពី*រឿងក្តី Gotovina* នៅទីនេះ ដូចនៅកន្លែងណាផ្សេងក៏ដោយ ក៏គាត់មិនបានពន្យល់ឲ្យងាយយល់ពីការចូលរួមរបស់ខ្លួន ឬការជំទាស់ទៅនឹងទឡ្ហីករណ៍នានាដែលសហមេធាវីបានលើកឡើងក្នុងសារណាឆ្លើយតបដែរ[29]។ ភាពជ្រើសរើសរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ក្នុងការឆ្លើយតបទៅនឹងបញ្ហាទំនាស់ផលប្រយោជន៍ក្នុង*រឿងក្តី Gotovina* ជាពិសេសនៅពេលគាត់ និងសហការីរបស់គាត់ពី ICTY-OTP បានចូលរួមនោះគឺជាការមិនលើកយកមកនិយាយយ៉ាងវ័យឆ្លាត។

[29] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ៩, ១៨។

25. អ.វ.ត.ក ពុំមានកាតព្វកិច្ចត្រូវអនុវត្តសេចក្តីណែនាំរបស់តុលាការ ICTY ស្តីពីការតែងតាំងមេធាវីការពារក្តីទេ អ.វ.ត.ក មាននីតិវិធីរបស់ខ្លួនផ្ទាល់។ ចំពោះទង្វើដែលនឹងធ្វើឱ្យថមថយនូវទំនុកចិត្តពីសាធារណជនទៅលើ អ.វ.ត.ក ឬ កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនោះ ចំណុចនេះត្រូវអនុវត្តចំពោះមេធាវី *និងព្រះរាជអាជ្ញា*ទាំងអស់ដែលកំពុងបំពេញការងារនៅ អ.វ.ត.ក។

26. កថាខណ្ឌ ៤៦ ដល់ ៤៧៖ ជាសំខាន់នោះគឺថា កថាខណ្ឌទាំងនេះលើកឡើងជាថ្មីនូវអ្វីដែលបានលើកឡើងក្នុងកថាខណ្ឌ ៤៥។ ចំពោះអ្វីដែលហៅថា យន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("MICT") វិញគឺថា វាគ្មានអ្វីក្រៅពីការបន្តនូវរបៀបរបបធ្វើការងារបច្ចុប្បន្ននៅតុលាការ ICTY និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ("ICTR") នោះទេ។ វាជាផ្នែកមួយនៃអ្វីដែលត្រូវបានគេយោងជាទូទៅថាជា "យន្តការសេសសល់") ក្នុងការឆ្លើយតបទៅនឹងការងារដែលហៀរហូរដែលគេរំពឹងថានឹងមាន បន្ទាប់ពីតុលាការ *មិនអចិន្ត្រៃយ៍*ទាំងពីរនេះបានបញ្ចប់ជាផ្លូវការប៉ុណ្ណោះ។ ការយោងទៅដល់ MICT មិនបានបន្ថែមតម្លៃពិតប្រាកដទេ។

27. កថាខណ្ឌ ៤៨៖ ដោយបានទទួលស្គាល់ថា លិខិតលះបង់សិទ្ធិត្រូវបានប្រើប្រាស់នៅតុលាការ ICTY នោះ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដកស្រង់*រឿងក្តី Prlić* ដើម្បីស្នើថាស្ថាប័នតុលាការត្រូវជឿថាត្រូវបំពេញតាមលក្ខខណ:វិនិច្ឆ័យមួយចំនួនជាមុនសិន មុននឹងទទួលយកលិខិតលះបង់សិទ្ធិ។ នោះជាគោលការណ៍នៅតុលាការ ICTY។ ទោះបីពុំមានយុត្តិសាស្ត្រអាចប្រៀបធៀបបាននៅ អ.វ.ត.ក ដូចដែលសហមេធាវីបានធ្វើជាតំណាងក៏ដោយ ក៏លក្ខណ:វិនិច្ឆ័យចាំបាច់ទាំងអស់ក្នុងការទទួលបានលិខិតលះបង់សិទ្ធពីលោក អៀង សារី និង លោក មាស មុត ត្រូវបានបំពេញហើយ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ទំនងជាបានផ្តល់យោបល់ថា ដើម្បីស្ថាប័នដែលពិនិត្យឡើងវិញទទួលយកនោះ ទាំង៖ (ក) សហមេធាវីនឹងចាំបាច់ត្រូវលាតត្រដាងនូវព័ត៌មានដែលជាបុព្វសិទ្ធិរវាងមេធាវីនិងកូនក្តី ឬ (ខ) លោក មាស មុត ដែលកំពុងស្ថិតក្រោមការស៊ើបអង្កេតសម្រាប់ជាគោលបំណងក្នុងការសម្រេចថា តើគាត់គួរត្រូវបានចោទប្រកាន់ចាប់ខ្លួន និងផ្តន្ទាទោស ឬយ៉ាងណានោះ ត្រូវតែលាតត្រដាងឱ្យដឹងនូវភាពជាក់លាក់នៃដំបូន្មានផ្លូវច្បាប់ដែលត្រូវផ្តល់ឱ្យគាត់ រួមទាំង "យុទ្ធសាស្ត្រការពារក្តី"/ទ្រឹស្តីនៃការការពារក្តីរបស់គាត់ផងដែរ។ នេះជាការមិនត្រឹមត្រូវទេ ហើយក៏មិនត្រូវបានគាំទ្រដោយយុត្តិសាស្ត្រណាមួយដែលអនុវត្តនៅ អ.វ.ត.ក ដែរ។ សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley គួរមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សំណើរបស់លោក មាស មុត ដែលសុំឱ្យមានសហមេធាវីតំណាងគាត់ ជាមធ្យោបាយ

ដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្ខិតបង្ខំសហមេធាវី ឲ្យរំលោភដល់ភារកិច្ចផ្ដល់ទំនុកចិត្តនៃបុព្វសិទ្ធិ/ភាពសម្ងាត់រវាងមេធាវីនិងកូនក្ដីផង និងឲ្យលោក មាស មុត លះបង់នូវសិទ្ធិរបស់គាត់តាមរដ្ឋធម្មនុញ្ញដើម្បីរក្សាភាពស្ងៀមស្ងាត់ និងមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងផងនោះទេ។

28. សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley បានដកស្រង់នូវយោបល់ផ្នែកក្រមសីលធម៌ពីគណៈមេធាវីនៅ District of Columbia ដើម្បីផ្ដល់ជាយោបល់ថា បុគ្គលដូចជាលោក មាស មុត មិនអាចដឹងពីលក្ខណៈនៃលិខិតលះបង់សិទ្ធិទេ ហើយហេតុនេះ សហមេធាវីមានភារកិច្ចតម្រែតម្រង់ឲ្យលោក មាស មុត ស្វែងរកដំបូន្មានពីមេធាវីខាងក្រៅ។ ជាថ្មីម្ដងទៀត យុត្តិសាស្ត្រនៅ អ.វ.ត.ក ពុំតម្រូវដូចអ្វីដែលគណៈមេធាវីនៅ District of Columbia បានលើកឡើងនៅក្នុងយោបល់ស្ដីពីក្រមសីលធម៌ទេ។ នៅក្នុងកាលៈទេសៈណាក៏ដោយ នៅក្នុងរឿងក្ដីដែលមានទំហំធំធេង និងមានលក្ខណៈស្មុគស្មាញដូចសំណុំរឿង ០០៣ គេពុំអាចដឹងច្បាស់ថានឹងត្រូវផ្ដល់យោបល់ទីពីរតាមរបៀបណា និងតាមកាលៈទេសៈណាខ្លះ ដោយមិនបានដឹងពីចំនួនតិចតួចនៃអង្គហេតុ កាលៈទេសៈ និងទង្វើដែលត្រូវបានចោទប្រកាន់ និងទង្វើដែលត្រូវបានចោទប្រកាន់នោះទេ មិនត្រឹមតែសម្រាប់លោក មាស មុត ទេ តែសូម្បីតែលោក អៀង សារី ក៏ដូច្នេះដែរ។ បន្ថែមទៅទៀត មេធាវីខាងក្រៅអាចនឹងធ្វើឲ្យប៉ះពាល់ទំនាក់ទំនងរវាងមេធាវីនិងកូនក្ដីដែលមានស្រាប់ ក្នុងគោលបំណងដើម្បីទទួលបាននូវការទុកចិត្តពីកូនក្ដី និងការតែងតាំងឲ្យកាន់រឿងក្ដីនេះ។ មានបញ្ហាច្រើនសន្ធឹកសន្ធាប់កើតឡើងដោយសារសំណើដែលសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley កំពុងស្នើឡើងនេះ។ ជាការគ្រប់គ្រាន់ហើយដែលនិយាយថា ពុំមានភស្តុតាងណាមួយ យ៉ាងហោចណាស់ក៏ពុំមានភស្តុតាងជាសាធារណៈទេដែលថា នៅក្នុង*រឿងក្ដី Gotovina* កូនក្ដីត្រូវបានតម្រូវឲ្យទទួលដំបូន្មានឯករាជ្យ ឬថា សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley លោក Kehoe ឬលោក Akhavan ស្វែងរក ឬខិតខំប្រឹងប្រែងដោយខ្លួនឯង ដើម្បីស្វែងរកដំបូន្មានឯករាជ្យទៅតាមយោបល់របស់គណៈមេធាវីនៅ District of Columbia នោះទេ។

## ខ. សារណាឆ្លើយតបទៅនឹងអង្គហេតុដែលពាក់ព័ន្ធ

29. កថាខណ្ឌ ៤៩-៥៣៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានអះអាងជាថ្មីម្តងទៀតនូវអ្វីដែលបានបង្ហាញក្នុងសំណើ [30] ទោះជាគាត់ផ្តល់ការតស៊ូមតិ និងធ្វើការបញ្ចេញបញ្ចូលបន្ថែមដើម្បីគាំទ្រអំណះអំណាងរបស់គាត់ថាលោក មាស មុត មានពិរុទ្ធភាពក៏ដោយ។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានចូលរួម ឬពាក់ព័ន្ធក្នុងយុទ្ធនាការចំហរជាសាធារណៈមួយដើម្បីប្រមូលផ្តុំការដាក់សម្ពាធអន្តរជាតិក្នុងការជំរុញឲ្យ ក.ស.ច.ស ធ្វើការចោទប្រកាន់ និងចាប់ខ្លួនជនសង្ស័យដែលត្រូវបានផ្តោតគោលដៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។[31] ដូច្នេះ លោក មាស មុត ពិតជាយល់ដឹងច្បាស់អំពីចេតនា*ពិតប្រាកដ* របស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ក្នុងការស្វះស្វែងឲ្យមានការកាត់សេចក្តី និងការផ្តន្ទាទោសរូបគាត់ ដូច្នេះហើយ វាមិនមែនជាផលប្រយោជន៍ល្អបំផុតសម្រាប់លោក មាស មុត ដែលត្រូវបោះបង់សិទ្ធិណាមួយរបស់គាត់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញឡើយ។

30. កថាខណ្ឌ ៥៤៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានយោងដោយមិនសមស្របចំពោះសេចក្តីរាយការណ៍នៅក្នុងសារព័ត៌មាន អំពីការទទួលស្វាគមន៍សហមេធាវីការពារក្តីនៅពិធីបុណ្យបូជាសព លោក អៀង សារី។ នេះមិនមានភាពជាប់ពាក់ព័ន្ធឡើយ ក្រៅពីបង្ហាញថា ក្រុមគ្រួសារលោកអៀង សារី បានសម្តែងអំណរគុណចំពោះអ្វីដែលសហមេធាវីការពារក្តី បានធ្វើតាងនាមឲ្យឪពុករបស់ពួកគេ និងនេះជាការគោរពគ្នាទៅវិញទៅមករវាងមេធាវីការពារក្តី និងកូនក្តី។ បញ្ហាទាំងនេះ ត្រូវបានលើកឡើងដើម្បីបង្ហាញថា វាជាក់ច្បាស់ថាមេធាវីការពារក្តីនឹងប្រាកដជាធ្វើឲ្យខូចប្រយោជន៍លោក មាស មុត កូនក្តីបច្ចុប្បន្នរបស់គាត់ ដោយសារថាកាតព្វកិច្ចរបស់មេធាវីការពារក្តីរបស់គាត់ក្នុងការតំណាងលោក អៀង សារី។ ទោះជាយ៉ាងនេះក្តី ការណ៍នេះបង្ហាញពីកម្រិតនៃការប្តេជ្ញាចិត្តរបស់សហមេធាវីការពារក្តី ដែលត្រូវអនុវត្តនៅពេលផ្តល់ការតំណាងតាមផ្លូវច្បាប់ដល់ជនសង្ស័យ ឬជនជាប់ចោទណាម្នាក់។ វាបង្ហាញពីចរិតនៃការតំណាងដែលលោក មាស មុត រំពឹងទទួលបានពីសហមេធាវីការពារក្តី។ ផ្អែកលើមូលដ្ឋានខាងលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងសហព្រះរាជអាជ្ញារងអន្តរជាតិ Smith ដែលម្តងម្កាលបំពេញតួនាទីជាសហ

---

[30] *សូមមើល* សំណើ កថាខណ្ឌ ៣៥-៤១

[31] *សូមមើលជាទូទៅ* សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញា http://www.eccc.gov.kh/en/media-center/press-releases

ព្រះរាជអាជ្ញាស្តីទីអន្តរជាតិ មើលទៅប្រហែលជាមានបំណងលុបបំបាត់មេធាវីការពារក្តីក្រុមនេះ ដែលចូលចិត្តតវ៉ាដេញដោល ឬយ៉ាងណា[32]។

31. កថាខណ្ឌ ៥៥-៥៦៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley យោងទៅលើគេហទំព័រដែលបង្កើតឡើងដោយសហមេធាវីការពារក្តីសម្រាប់រឿងក្តី លោកអៀង សារី។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មានចេតនាបំភាន់លោកសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon ដោយអះអាងថា គេហទំព័រ និងសេចក្តីដកស្រង់នៅក្នុងកថាខណ្ឌ ៥៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ជាអ្វីមួយថ្មី។

32. សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដឹង (ឬគួរដឹង)ថាគេហទំព័រនោះ ត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ ២00៩ មកម្ល៉េះ[33]។ ការដកស្រង់នោះជាសេចក្តីថ្លែងការណ៍អំពីគោលដៅនៃគេហទំព័រចាស់ ដែលបង្ហាញយ៉ាងច្បាស់នៅគេហទំព័រដើម/ទំព័របើក។[34] គេហទំព័រនេះ ត្រូវបានបង្កើតឡើងសម្រាប់គោលបំណងបង្ហាញពីតម្លាភាព ដោយគិតដល់ភាពទន់ខ្សោយជាប្រព័ន្ធមួយចំនួន និងទំនោរនៃការបិទបាំងនៅ អ.វ.ត.ក[35]។ គេហទំព័រថ្មី គ្រាន់តែជាកំណែថ្មីដែលធ្វើឲ្យ

---

[32] ជារឿយៗ សហព្រះរាជអាជ្ញាស្តីទីអន្តរជាតិ Smith បានបញ្ចេញទស្សនៈ ថាមេធាវីការពារក្តីលោក អៀង សារី និងជាពិសេសលោកមេធាវី Karnavas មិនបង្អង់ដៃ ។ ទោះជាយ៉ាងណា ចំណុចនេះ បង្ហាញការសរសើរចំពោះគុណភាពខ្ពស់ និងទំហំការងារជាច្រើនដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីលោក អៀង សារី ទៅវិញ។

[33] *សូមមើល* គេហទំព័រចាស់របស់ក្រុមមេធាវីការពារក្តីលោក អៀង សារី, *សូមមើលផងដែរ* នៅលើគេហទំព័រ៖ https//sites.google.com/site/IENGsarydefence/។ សេចក្តីថ្លែងការណ៍ព័ត៌មានរបស់ក្រុមមេធាវីការពារក្តីស្តីពីការរំលោភបំពានលើភាពសម្ងាត់ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២00៩។ សេចក្តីថ្លែងការណ៍ព័ត៌មានរបស់ក្រុមមេធាវីការពារក្តីអំពីការដកចេញឯកសាររបស់ក្រុមមេធាវីការពារក្តីពីគេហទំព័រ, ថ្ងៃទី ៨ ខែ មីនា ឆ្នាំ២00៩។

[34] *សូមមើល* គេហទំព័រចាស់របស់ក្រុមមេធាវីការពារក្តីលោក អៀង សារី, *សូមមើលផងដែរ* នៅលើគេហទំព័រ៖ https//sites.google.com/site/IENGsarydefence/។

[35] *ដូចជើងទំព័រខាងលើ* សូមមើល សេចក្តីថ្លែងការណ៍ព័ត៌មានរបស់ក្រុមមេធាវីការពារក្តីស្តីពីការរំលោភបំពានលើភាពសម្ងាត់ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២00៩។ សេចក្តីថ្លែងការណ៍ព័ត៌មានរបស់ក្រុមមេធាវីការពារក្តីអំពីការដកចេញឯកសាររបស់ក្រុមមេធាវីការពារក្តីពីគេហទំព័រ, ថ្ងៃទី ៨ ខែ មីនា ឆ្នាំ២00៩។ *សូមមើលផងដែរ* លិខិតរបស់លោក Michael G. Karnavas សហមេធាវីការពារក្តីអន្តរជាតិ ផ្ញើជូនគណៈមេធាវី Alaska ជាការឆ្លើយតបទៅនឹងបណ្តឹងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មានចំណងជើងថា “សារណាឆ្លើយតបទៅនឹងបណ្តឹងជាប់ទាក់ទងនឹង*ដីកាសម្រេចស្តីពីការរំលោភបំពានលើភាព*

មានភាពប្រសើរជាងគេហទំព័រចាស់/គេហទំព័រដើមតែប៉ុណ្ណោះ។ គេហទំព័រថ្មី មានភាពខុសគ្នាតែមួយប៉ុណ្ណោះ គឺមានភាពងាយស្រួលប្រើជាងសម្រាប់អ្នកដែលចាប់អារម្មណ៍សិក្សាស្រាវជ្រាវ។ គេហទំព័រនេះមិនមានអ្វីអាក្រក់ឡើយ។ អត្ថបទដែលបានដកស្រង់ មិនប៉ះពាល់ដល់បញ្ហានាពេលបច្ចុប្បន្នឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley លើកឡើងថា គេហទំព័រនេះជាភស្តុតាងនៃការបន្តភក្តីភាពរបស់សហមេធាវីការពារក្តីចំពោះលោក អៀង សារី ហើយប្រាកដជារារាំងសមត្ថភាព ឬឆន្ទៈក្នុងការបំពេញកាតព្វកិច្ចការពារក្តីផ្តល់ទំនុកចិត្ត ប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈដល់លោក មាស មុត ។ នេះជាការលើកឡើងគួរឲ្យអស់សំណើច។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ពិតជាបានចូលរួមធ្វើការវាយប្រហារ*ជាបុគ្គល* ដោយលាក់មុខ ក្នុងគោលបំណងអុជអាល និងធ្វើឲ្យប៉ះពាល់ដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

## គ. សារណាឆ្លើយតបទៅនឹងទទ្បីករណ៍

### ១. មិនមានទំនាស់ផលប្រយោជន៍ឡើយ

33. កថាខណ្ឌ ៥៧-៦៩៖ វាជាការគួរឲ្យអស់សំណើចដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានលើកឡើងជាថ្មីម្តងទៀតនូវអំណះអំណាងតាមបែបឧបមាណវិធីនៅក្នុងសំណើ។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនយល់ច្បាស់ថាតើមេធាវីការពារក្តី មានបំណងការពារក្តីលោក មាស មុត ដោយវិធីណាឡើយ។ គាត់ពិតជាមិនដឹងអ្វីទាល់តែសោះអំពីទ្រឹស្តីនៃរឿងក្តី និងយុទ្ធសាស្ត្រដែលជ្រើសរើសដោយលោក មាស មុត ផ្អែកលើការពិគ្រោះយោបល់ជាមួយសហមេធាវីការពារក្តីរបស់គាត់។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនមែនជាផ្នែកមួយនៃការប្រាស្រ័យទាក់ទងគ្នារវាងមេធាវី និងកូនក្តីឡើយ។ នេះគ្រាន់តែជាអ្វីដែលគាត់យល់ឃើញប៉ុណ្ណោះ។

34. ផ្អែកលើការសន្និដ្ឋានតាមបែបឧបមាណវិធីដែលបម្រើផលប្រយោជន៍ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ Cayley អះអាងថាផលប្រយោជន៍ផ្លូវច្បាប់របស់លោក អៀង សារី និងមាស មុត "មានភាពប្រទាំងប្រទិសគ្នាយ៉ាងជាក់ស្តែង" និង "មានទំនាស់ផលប្រយោជន៍ជាច្រើន"។ គាត់ដក

---

*សម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ* ដែលគណៈមេធាវី Alaska បានទទួលនៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩, www.iengsarydefence.org ។

ស្រង់សេចក្ដីរាយការណ៍ក្នុងសារព័ត៌មានមួយ និងបានសំដៅលើលោក មាស មុត ដើម្បីបង្ហាញថា វាជាភស្តុតាងនៃផលប្រយោជន៍តាមផ្លូវច្បាប់ដែលប្រទាំងប្រទិសគ្នាយ៉ាងច្បាស់ក្រឡែត។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានបញ្ជាក់ពីចំណុចនេះនៅក្នុងសំណើ[36] ដោយលើកឡើងជាថ្មី ឬធ្វើការបញ្ចេញបញ្ចូលតាមការប៉ាន់ស្មានលើអ្វីដែលមិនមានមូលដ្ឋានច្បាស់លាស់។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនដឹងច្បាស់ពីអ្វីដែលត្រូវបានលើកឡើង មិនដឹងពីបរិបទ និងមិនដឹងមូលហេតុខ្លះឡើយ។ គាត់គ្រាន់តែអាចដឹងថាវា*ពិតប្រាកដ* និង*អាចដឹងបាន*តែប៉ុណ្ណោះ។ វាមិនសមហេតុផលឡើយដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley លើកឡើងថា គប្បីត្រូវថ្លឹងថ្លែង ឬពិចារណាឲ្យបានដិតដល់នូវការដកស្រង់សេចក្ដីពីសារព័ត៌មានមួយចំនួន ដែលមានការចុះកាលបរិច្ឆេទ ជាពិសេសទោះជាមិនដឹងប្រាកដពីការដកស្រង់សេចក្ដីទាំងអស់ក៏ដោយ។

35. ដូចបានលើកឡើងខាងលើ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដែលថាគេហទំព័រថ្មីជាភស្តុតាងបង្ហាញថា សហមេធាវីការពារក្ដីកំពុងបន្តការពារក្ដី និងបុព្វហេតុរបស់លោក អៀង សារី និងប៉ះពាល់យ៉ាងជាក់ច្បាស់ដល់ផលប្រយោជន៍របស់លោក មាស មុត នោះ (កថាខណ្ឌ ៦៥-៦៦) មិនសមហេតុផលឡើយ។ គេហទំព័រនេះ ជាការងារកំពុងដំណើរការដែលត្រូវការពេលវេលា និងធនធានដើម្បីបង្ហោះក្នុងគេហទំព័រនូវសារណាដែលបានដាក់ក្នុងរយៈពេលជាង៥ឆ្នាំកន្លងមក (មានសារណាចំនួន ៤៥០ ដោយមិនរួមបញ្ចូលការឆ្លើយឆ្លងមិនសម្ងាត់ ដូចជាសារអេឡិចត្រូនិក លិខិត និងអនុស្សរណៈ)។ ដូចបានកត់សម្គាល់ខាងលើ និងអាចមើលឃើញយ៉ាងច្បាស់នៅលើគេហទំព័រស្រាប់ថា គេហទំព័រនោះគឺជាឧបករណ៍សម្រាប់ការសិក្សាស្រាវជ្រាវ និងអាចចាត់ទុកជាផ្នែកមួយនៃកេរដំណែលរបស់អ.វ.ត.ក។ គេហទំព័រនោះ ជូនដំណឹងដល់សាធារណៈជនអំពីឯកសារ ដែលសហមេធាវីការពារបានដាក់ក្នុងការតំណាងលោក អៀង សារី ក្នុងសំណុំរឿង ០០២។ គេហទំព័រនោះ ពិតជាមានអត្ថបទ និងសេចក្ដីប្រកាសព័ត៌មានមួយចំនួនមែន ក៏ប៉ុន្តែគេហទំព័រនោះមិនផ្ដល់ការការពារក្ដីឲ្យលោក អៀង សារី ឡើយ។ ដោយហេតុថាឯកសារ និងសារណាសម្ងាត់ ត្រូវបានដាក់ចំណាត់ថ្នាក់ឡើងវិញ ជាឯកសារ "សាធារណៈ"នោះ វាចាំបាច់ត្រូវបង្ហោះឯកសារទាំងនោះចូលក្នុងគេហទំព័រ ដើម្បីឲ្យសាធារណៈជនអាចរកឯកសារ

[36] សំណើ កថាខណ្ឌ ៤៣។

ទាំងនោះបាន។ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ទាក់ទងនឹងគេហទំព័រនោះមិនសមស្របឡើយ។

**២. ទំនាស់ផលប្រយោជន៍ អាចត្រូវបានលើកលែង**

36. កថាខណ្ឌ ៧០៖ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដែលថាការចូលរួមរបស់សហមេធាវីការពារក្ដីក្នុងសំណុំរឿង ០០៣ (និង ០០៤) នឹងបណ្ដាលឲ្យ "ប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" និងធ្វើឲ្យប៉ះពាល់កិច្ចការរដ្ឋបាលតុលាការ មិនមានមូលដ្ឋានឡើយ។ *ផ្ទុយពីអ្វីដែលជាការប្រឌិត* វាពិបាកយល់ថាតើការការពារក្ដីយ៉ាងខ្លាំងក្លាដែលលោក មាស មុត រំពឹងទទួលបាន (ផ្អែកលើការតំណាងកូនក្ដីដែលមេធាវីការពារក្ដីក្រុមនេះ ត្រូវបានទទួលស្គាល់ និងដូចអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិ Smith បានទទួលស្គាល់នោះ[37]) នឹងមានឥទ្ធិពលលើមតិសាធារណៈជន ឬមាន "ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" ជាក់ស្ដែងចំពោះមុខមាត់ អ.វ.ត.ក ឬកិច្ចការរដ្ឋបាលតុលាការយ៉ាងណា។ ការអះអាងទាំងនេះ មិនសមស្រប មិនមានការទទួលខុសត្រូវ និងស្ទើរតែជាលក្ខណៈបុគ្គល[38]។

---

[37] *សូមមើល* ជើងទំព័រលេខ ៣២ *ខាងក្រោម*។

[38] សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley អាចគ្រាន់តែលើកឡើងនូវអំណះអំណាងបែបនេះដោយសារមានគំនុំជាមួយសហមេធាវី ដោយសារតែសហមេធាវីធ្លាប់បានធ្វើសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងលិខិតទំនាក់ទំនងការងារ *ជាមួយភាគីតែម្ខាង*ដែលៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley។ *សូមមើល រឿងក្ដី នួន ជា និងជនផ្សេងទៀត,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, សំណើរបស់លោក អៀង សារី ស្នើឲ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងការងារ *តែភាគីម្ខាង*រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និង អ្នកដទៃទៀត, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារ E137/3; *សំណុំរឿង នួន ជា និងជនផ្សេងទៀត,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, បណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្ដឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwright, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២, ឯកសារ E137/5/1/1; *សំណុំរឿង នួន ជា និងជនផ្សេងទៀត,* ០០២/១៩-០៩-២០០៧-អវតក/អជសដ, បណ្ដឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwright អនុលោមតាមវិធាន ៣៤ ឬជាជម្រើសផ្សេង សំណើសុំការណែនាំ និងបង្គាប់ឲ្យបញ្ឈប់ និងឈប់ការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង (ex parte)* និង សំណើសុំឲ្យបញ្ចេញឲ្យដឹងអំពីការប្រាស្រ័យទាក់ទងនានាជាមួយ *តែភាគីម្ខាង (ex parte)*, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារ E191។ គួរកត់សម្គាល់ផងដែរពីការសន្ទនាជាឯកជនដែលធ្វើឡើងនាពេលមួយក្នុងខែ វិច្ឆិកា ឆ្នាំ ២០១២ រវាង សហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley ជាមួយសហការីគាត់ម្នាក់មកពីចក្រភពអង់គ្លេស ដែលក្នុងអំឡុងពេលនោះ គាត់បានកត់សម្គាល់ថា គាត់មានសារមួយដែលគាត់ចង់ផ្ដាំផ្ញើទៅលោក Karnavas ថា គាត់នឹងដកលោក Karnavas ចេញពីសំណុំរឿង ០០៣ ចំពោះការដែលព្យាយាមតំណាងជនសង្ស័យមួយរូបដែលមានឈ្មោះក្នុងសំណុំរឿង ០០២ ដែរ។ សហព្រះរាជអាជ្ញាអន្តរជាតិ

37. ដូចការកត់សម្គាល់ខាងលើ នៅ ICTY មានឧទាហរណ៍ច្រើនឥតគណនា ដែលមេធាវីការពារក្តីបានចូលរួមការពារកូនក្តីច្រើនជាងមួយរូបក្នុងសំណុំរឿង ដែលមានអង្គហេតុជាប់ពាក់ទាក់ទងគ្នា។ រឿងក្តី Srebrenica ជាឧទាហរណ៍ដ៏ល្អមួយ។ រឿងក្តីនោះ ត្រូវបានកត់ត្រាជាសាធារណៈ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិ Carley និង Smith ស្គាល់មេធាវីដែលកំពុងចូលរួមការពារក្តីឱ្យ Mladić និងការចូលរួមពីមុនក្នុងរឿងក្តីផ្សេងទៀត។ ឧទាហរណ៍ មេធាវីការពារក្តី Nenad Petrušić ជាមេធាវីការពារក្តីនាំមុខឱ្យឧត្តមសេនីយ៍ Krstić ដែលជាមេបញ្ជាការពិតប្រាកដរបស់ Drina Corps ដែលស្ថិតនៅក្រោមការគ្រប់គ្រងរួមរបស់ឧត្តមសេនីយ៍ Mladić។ នៅពេលនោះ លោក Petrušić ជាសហមេធាវីការពារក្តីឱ្យឧត្តមសេនីយ៍ Mladić ដែលចូលរួមពាក់ព័ន្ធជាមួយ Main Staff ដែលត្រួតត្រាលើ Drina Corps ដែលនៅក្រោមការគ្រប់គ្រងរបស់ឧត្តមសេនីយ៍ Mladić។ បច្ចុប្បន្ននេះ លោក Petrušić ជាសមាជិកដ៏សំខាន់មួយរូបនៅក្នុងក្រុមអ្នកច្បាប់របស់ឧត្តមសេនីយ៍ Mladić[39]។ ករណីលោក Petrušić មិនមែនករណីតែមួយទេ។ ដូចបានកត់សម្គាល់ក្នុងសារណាឆ្លើយតប ឧត្តមសេនីយ៍ Mladić ត្រូវបានការពារក្តីដោយមេធាវីពីររូបផ្សេងទៀត ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងរឿងក្តី Srebrenica ផ្សេងទៀត[40]។ OTP បានលើកឡើងពីការកង្វល់នៃ "ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" ក្នុងរឿងក្តីនេះ។

38. សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ធ្វើការអះអាងលឿនពេកអំពី "ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" ចំពោះ អ.វ.ត.ក បើសិនសហមេធាវីការពារក្តីត្រូវការពារក្តីឱ្យលោក មាស មុត។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ឬ ក.ស.ព ដែលជាស្ថាប័នមួយ មិនបានដម្លែងនូវការភ្ញាក់ផ្អើលឡើងនៅពេលអ្នកវិភាគមួយរូបនៅ ក.ស.ព ដែលទទួលខុសត្រូវព្រាងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរសំណុំរឿង ០០២ បានប្តូរទៅធ្វើការនៅ ក.ស.ច.ស និងមានតួនាទីអ្នកវិភាគនៅក្នុងការស៊ើប

---

លោក Cayley បានជូនដំណឹងទៅលោក Karnavas ថា ការពិតកិច្ចសន្ទនានេះពិតជាបានកើតឡើងមែន តែថា គាត់ស្រវឹងនាពេលនោះ ដែលអាចនាំឱ្យនិយាយប៉ប៉ាច់ប៉ប៉ោចមែននេះ។

[39] ទោះបីលោក Perušić ពុំមែនជាមេធាវី ឬសហមេធាវីនៃកំណត់ត្រានោះក៏ដោយ ក៏គាត់នៅតែមានកាតព្វកិច្ចផ្តល់ទំនុកចិត្តដល់កូនក្តីពីមុនរបស់គាត់គឺឧត្តមសេនីយ៍ Krstić និង ឧត្តមសេនីយ៍ Miletić ដែរ។ ហេតុនេះ ទោះបីគាត់មានតួនាទីនៅក្នុងក្រុមអ្នកច្បាប់ការពារក្តីឧត្តមសេនីយ៍ Mladić ក៏ដោយ ក៏គាត់មិនមានសេរីភាពក្នុងបញ្ចេញព័ត៌មានសម្ងាត់ដែលគាត់បានទទួលកាលពីនៅជាតំណាងឧត្តមសេនីយ៍ Krstić និង ឧត្តមសេនីយ Miletić តាមចិត្តដែរ ហើយគាត់ពិតជាមិនគួរចូលរួមជួយការពារក្តីដែលផ្តល់ប្រយោជន៍ដល់ឧត្តមសេនីយ៍ Mladić ដោយធ្វើឱ្យមានមហន្តរាយដល់ឧត្តមសេនីយ៍ Krstić និង ឧត្តមសេនីយ៍ Miletić ដែរ។

[40] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ២១។

អង្កេតទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងតែមួយនោះឡើយ[41]។ ស្រដៀងគ្នានេះ (ទោះជាត្រូវបានមើលឃើញយ៉ាងច្បាស់យ៉ាងណាក៏ដោយ) សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនបានសម្តែងការភ្ញាក់ផ្អើលចំពោះ "ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ" នៃការប្រាស្រ័យ *ជាមួយភាគីតែម្ខាង* ដែលបន្តធ្វើឡើងជាមួយចៅក្រមមួយរូបនៃអង្គជំនុំជម្រះសាលាដំបូងឡើយ ទោះជាបន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូល ធ្វើការកត់សម្គាល់ថាការប្រព្រឹត្តរបស់គាត់ បណ្តាលឲ្យមានទំនាក់ទំនងមិនស្មើភាពគ្នា ដែលធ្វើឲ្យសាធារណជនយល់ឃើញថា ក.ស.ព កំពុងធ្វើការរួមគ្នាជាមួយអង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើឲ្យខូចប្រយោជន៍ជនជាប់ចោទក៏ដោយ[42]។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនបានសម្តែងការភ្ញាក់ផ្អើលចំពោះការវាយប្រហារបើកចំហរជាសាធារណៈរបស់គាត់លើភាពមិនប្រក្រតីជាក់ស្តែង ឬត្រូវបានមើលឃើញរបស់ ក.ស.ចៃ.ស ដែលបានប្រព្រឹត្តឡើងដោយចៅក្រម Blunk សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅពេលនោះ និងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ក្នុងសំណុំរឿង 00៣ និងសំណុំរឿង 00៤ឡើយ[43]។

---

[41] *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/អជសដ, សំណើរបស់ អៀង សារី ស្នើសុំព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញដែលមានរហស្សនាម TCE-33, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២, ឯកសារ E236/2/2; *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/អជសដ, សំណើរបស់សហព្រះរាជអាជ្ញាសុំស្តាប់សក្ខីកម្មអ្នកជំនាញ ២ រូប និង សាក្សី ១៣ រូបបន្ថែមទៀតនៅក្នុងដំណើរការជំនុំជម្រះដំបូងនៃសវនាការ និងការជូនដំណឹងពីការស្នើសុំដាក់ឈ្មោះដែលរៀបរាប់ខ្លីៗចំនួន ៧ ដែលពាក់ព័ន្ធនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៨៧(៤), ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារ E93/7, កថាខណ្ឌ ៩; *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/អជសដ, សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ដែលមានសក្តានុពល, ថ្ងៃទី ១0 ខែ មករា ឆ្នាំ ២00៨, ឯកសារ A121; *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/អជសដ, លិខិតរបស់ ក.ស.ចៃ.ស ផ្ញើជូនមេធាវីការពារក្តីមានចំណងជើងថា សំណើសុំផ្តល់ព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាលាយលក្ខណ៍អក្សរ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២00៨, ឯកសារ A121/I, ទំព័រ ១។

[42] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក/អជសដ, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងជំទាស់ចៅក្រម Silvia Cartwright, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១២, ឯកសារ E137/5/1/3, កថាខណ្ឌ ២៤។

[43] *សូមមើលឧទាហរណ៍,* សេចក្តីប្រកាសព័ត៌មានដោយសហព្រះរាជអាជ្ញាអន្តរជាតិលោក Cayley, សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង 00៣, ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១; សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ, សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង 00៤, ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១១; បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងការបដិសេធន៍សំណើសុំស៊ើបអង្កេតក្នុងសំណុំរឿង 00៣, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១។ អត្តសញ្ញាណរបស់លោក មាស មុត ជាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យ

39. កថាខណ្ឌ៧១៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley នៅតែបន្តប៉ាន់ស្មាននៅពេលអះអាងថា កិច្ចការរបស់ អ.វ.ត.ក នឹងទទួលរងផលប៉ះពាល់ បើសិនជាសហមេធាវីការពារក្តីក្រុមនេះតំណាងឲ្យលោក មាស មុត។ ឧទាហរណ៍គួរឲ្យចាប់អារម្មណ៍មួយដែលបង្ហាញពីភាពផ្ទុយគ្នានៃកង្វល់របស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley គឺនៅពេលដែលសហព្រះរាជអាជ្ញារងអន្តរជាតិ Smith ធ្វើអន្តរាគមន៍ម្តងហើយម្តងទៀតក្នុងអំឡុងពេលសួរដេញដោល ឌុច ក្នុងសំណុំរឿង ០០២/០១ ថា ជនសង្ស័យ ឬជនជាប់ចោទ គួរទទួលបាន "ឱកាសទាំងអស់ដើម្បីទទួលបានការការពារក្តីឲ្យបានពេញលេញ"។ នៅពេលនោះ គាត់បានបកស្រាយខុសថាមានលទ្ធភាពដែល ឌុច អាចត្រូវបានជំនុំជម្រះក្តីបន្ថែមទៀត ដូច្នេះគាត់បានលើកឡើង (និងស្ទើរតែណែនាំដល់ឌុច) ថាសំណើរបស់ឌុចសុំសិទ្ធមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង គួរត្រូវបានទទួលយក[44]។ បន្ទាប់មកទៀត អ្វីដែលគួរឲ្យអស់សំណើចបំផុត និងជាការលាក់ពុតនោះ គឺនៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley និង Smith បានជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីណែនាំរំលឹកមួយដល់សាក្សីថា ពួកគាត់មិនត្រូវខ្លាចទទួលរងការចោទប្រកាន់ទេ ដោយសារស្ទើរតែគ្មានលទ្ធភាពបែបនេះសោះឡើយ[45]។

40. វាជ្រុលពេកហើយ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បង្ហាញកង្វល់អំពីសិទ្ធិនៃការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់លោក មាស មុត។ កំណត់ត្រាសំណុំរឿង ០០២ បង្ហាញយ៉ាងច្បាស់ថានៅពេលមានប្រយោជន៍ដល់ ក.ស.ព សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មានទំនោរអនុវត្តយុទ្ធវិធី ដែលអាចចោទសួរបានក្នុងការបំពានលើសិទ្ធិការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់លោក អៀង សារី ដោយខ្លួនលោកផ្ទាល់ ឬតាមរយៈអ្នកនៅក្រោមបង្គាប់គាត់។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ជាអ្នកគាំទ្រម្នាក់ជំរុញឲ្យផ្តន្ទាទោស លោក មាស មុត តាមរយៈសារព័ត៌មាន។

---

ក្នុងសំណុំរឿង ០០៣ នៅពេលនេះត្រូវបានយកមកពិភាក្សានៅក្នុងសារព័ត៌មាន។ *សូមមើលឧទាហរណ៍* James O'Toole, *Cayley in the Crosshairs*, កាសែតភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១១។

[44] *សូមមើលឧទាហរណ៍ សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, ប្រតិចារឹក, ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ឯកសារ E1/58.1, ទំព័រ ៧៤ (ភាសាអង់គ្លេស)។

[45] *សូមមើល សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ, សំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២, ឯកសារ E200; *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/ អជសដ, សំណើជាបន្ទាន់របស់លោក អៀង សារី សុំអនុញ្ញាតពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតផ្តល់ការធានាទាក់ទងទៅនឹងការមិនចោទប្រកាន់សាក្សី, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ E200/1។

ដូច្នេះ អ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley ចង់បានបំផុតក្នុងសំណុំរឿង 00៣ នោះ គឺក្រុមការពារក្ដីដែលមិនបង្អង់ដៃ និងពូកែតវ៉ាដេញដោល ឲ្យមកធ្វើតំណាងលោក មាស មុត។

41. កថាខណ្ឌ ៧២៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ផ្ដល់អំណះអំណាងបន្ថែមដែលមានលក្ខណៈទូទៅ និងមិនមានមូលដ្ឋានថា ទោះជាយ៉ាងណាក៏ដោយ- ផ្អែកលើយុត្តិសាស្ត្រដែលបានដកស្រង់ - លោក មាស មុត នឹងមិនទទួលបានការការពារក្ដីយ៉ាងខ្លាំងក្លាឡើយ ដោយសារអសមត្ថភាពជាក់ស្ដែងមួយចំនួនរបស់សហមេធាវីការពារក្ដីដែលត្រូវបានមើលឃើញ។ រឿងក្ដីទាំងនេះ មានអង្គហេតុជាក់លាក់ និងមិនជាប់ទាក់ទងនឹងអង្គហេតុបច្ចុប្បន្នឡើយ។

42. កថាខណ្ឌ ៧២៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley អះអាងថាបើសិនជាសហមេធាវីការពារតំណាំងលោក មាស មុត នោះ វានឹងប៉ះពាល់ដល់សុច្ចរិតភាពនៃសំណុំរឿង 00២ ដោយហេតុថាលោក មាស មុត មានឈ្មោះក្នុងបញ្ជីសាក្សីនៃសំណុំរឿង 00២។ គួរឲ្យកត់សម្គាល់ថាសហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានដាក់លោកមាស មុត នៅលើផ្ទាំងស៊ីបរបស់ក.ស.ព ជាសាធារណៈ។

43. សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានប្រកាសជាសាធារណៈថាលោក មាស មុត ស្ថិតនៅក្នុងក្របខ័ណ្ឌយុត្តាធិការរបស់អ.វ.ត.ក។ គាត់ចូលរួមពាក់ព័ន្ធជាមួយបណ្ដឹងរបស់សាធារណៈជនដែលចោទថាអ្នកខាងក្នុង (អ.វ.ត.ក) និងអ្នកខាងក្រៅ (រដ្ឋាភិបាលកម្ពុជា) កំពុងត្រូវបានបង្ខំឲ្យការពារដើម្បីកុំឲ្យនាំខ្លួនជនសង្ស័យក្នុងសំណុំរឿង 00៣ និង00៤ មកជំនុំជម្រះក្ដី[46]។ បញ្ហាទាំងនេះត្រូវបានពិភាក្សាយ៉ាងក្ដៅគគុកជាសាធារណៈ និងនៅក្នុងព័ត៌មានកម្ពុជា (សារព័ត៌មាន, វិទ្យុ និងទូរទស្សន៍)។ ដូច្នេះ លោក មាស មុត ពិតជាដឹងយ៉ាងច្បាស់អំពីលទ្ធភាពនៃការចោទប្រកាន់, ការចាប់ខ្លួន និងការជំនុំជម្រះក្ដីលើខ្លួនគាត់។

---

[46] *ជើងទំព័រខាងលើ* លេខ ៣១។ *សូមមើលផងដែរ* លិខិតផ្ញើជូនរដ្ឋមន្ត្រីការបរទេស ស.រ.អា លោកស្រី Hillary Clinton, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, *អាចរកបាននៅលើគេហទំព័រ៖* http://sites.google.com/site/IENGsarydefence/; លិខិតផ្ញើជូននិពន្ធនាយក, គោលនយោបាយការបរទេស, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, *អាចរកបាននៅលើគេហទំព័រ៖* http://sites.google.com/site/IENGsarydefence/។ *សូមមើលផងដែរ* អង្គការយុត្តិធម៌សង្គមសេរី, *ការវិវត្តន៍នាពេលថ្មីៗនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (Recent Developments at the Extraordinary Chambers of the Courts of Cambodia),* ខែ កុម្ភៈ ឆ្នាំ ២០១២, *អាចរកបាននៅលើគេហទំព័រ៖* http://www.soros.org/sites/defaults/files/cambodia-eccc-20120233.pdf។

44. លោក មាស មុត បានដឹងពីសិទ្ធិរបស់គាត់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ គាត់មានសិទ្ធិមិនផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីមួយ- ដែលសហព្រះរាជអាជ្ញាមានគោលបំណង ចម្រាញ់រកភស្តុតាងដាក់បន្ទុក ដែលអាចជួយ ក.ស.ច.ស ក្នុងការបំពេញកិច្ចស៊ើបអង្កេត និង/ឬសម្រាប់ការជំនុំជម្រះក្តីនាពេលអនាគត។ លោក មាស មុត ក៏បានដឹងថាឌុច បានសហការ និងផ្តល់សក្ខីកម្ម និងសារភាពក្នុងអំឡុងពេលសវនាការជំនុំជម្រះក្តីលើរូបគាត់ ប៉ុន្តែសហព្រះរាជអាជ្ញា មិនបានផ្តល់អ្វីជាការដោះដូរឡើយ។ នេះជាការលើកឡើងដ៏ជូរចត់ជាសាធារណៈដោយលោក Francois Roux មេធាវីអន្តរជាតិការពារឲ្យក្តីឌុចនៅពេលនោះ[47]។ ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខសហព្រះរាជអាជ្ញាអន្តរជាតិ Cayley មានវត្តមាន នៅពេលដែល ក.ស.ព លើកទឡ្ហីករណ៍គាំទ្រឲ្យបន្ថែមទម្ងន់ទោសដល់ឌុច។ រឿងរ៉ាវទាំងអស់នេះ បានចុះផ្សាយជារឿយៗក្នុងសារព័ត៌មាន។ ដូច្នេះ លោក មាស មុត អាចដឹងជាមុនថាតើត្រូវរំពឹងអ្វីពី ក.ស.ព និងជាពិសេសពីសហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងព្រះរាជអាជ្ញារងអន្តរជាតិ Smith។

45. ដោយសារលោក មាស មុត បានដឹងបញ្ហាទាំងអស់ខាងលើនេះ គាត់បានជូនដំណឹងយ៉ាងច្បាស់អំពីការស្នើអនុវត្តសិទ្ធិមានចែងក្នុងរដ្ឋធម្មនុញ្ញដោយមិនផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ឡើយ។ វាមិនមានមូលដ្ឋានឡើយក្នុងការលើកឡើថាសហមេធាវីការពារក្តី បានប៉ុនប៉ង ឬមានបំណងធ្វើឲ្យប៉ះពាល់លទ្ធផលក្នុងសំណុំរឿង ០០២ ក្នុងការតំណាងលោក មាស មុត ក្នុងសំណុំរឿង០០៣។ លើសពីនេះ វាមិនសមហេតុផលឡើយដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley អះអាងថាការសម្រាលទោស ទំនងជាកើតមាន បើសិនជាសហមេធាវីការពារក្តីលាលែង និងផ្តល់ឱកាសឲ្យមេធាវីការពារក្តីដទៃទៀតដែលមានចេតនាល្អជាងនេះ ដើម្បីផ្តល់ប្រឹក្សាយោបល់សមស្របដល់លោក មាស មុតនោះ។

46. កថាខណ្ឌ ៧៤៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley នៅតែធ្វើការប៉ាន់ស្មានដែលមិនមានមូលដ្ឋានទាល់តែសោះថា សហមេធាវីការពារក្តី មានផលប្រយោជន៍បុគ្គលក្នុងលទ្ធផល ០០២ ទោះជាលោក អៀង សារី បានទទួលមរណភាពហើយក្តី។ សហមេធាវីការពារក្តី នៅបន្តកាតព្វកិច្ចផ្តល់ទំនុកចិត្តដល់លោក អៀង សារី ដូចបានទទួលស្គាល់ក្នុងសារណាឆ្លើយតបនេះ។ ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចផ្តល់ទំនុកចិត្តដែលបន្តមាន មិនពាក់ព័ន្ធនឹង “ផលប្រយោជន៍បុគ្គល

---

[47] *សូមមើល* សារណាឆ្លើយតប, កថាខណ្ឌ ៣៧ ដល់ ៣៨។

ដើម្បីធ្វើឱ្យទឡ្ហីករណ៍ដែលមេធាវីការពារក្តីគាំទ្រក្នុងសំណុំរឿង ០០២ មានភាពសមស្រប និងមតិយោបល់ដែលលើកឡើងជាសាធារណៈមានលក្ខណៈសមហេតុផល" ដូចបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ Cayley នោះទេ។ ការលើកឡើងនោះ មិនសមហេតុផល និងមិនអាចទទួលយកបានឡើយ។

47. សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដកស្រង់ជាភ័ស្តុតាងនូវសម្តីរបស់លោក Karnavas ដែលបានចុះផ្សាយនៅក្នុងសារព័ត៌មាន Toronto Star ដែលមិនផ្តល់ការគាំទ្រអ្វីឡើយចំពោះភាពមិនសមហេតុផលដែលថាសហមេធាវីការពារក្តី កំពុងបន្តព្យាយាមផ្តល់យុត្តិកម្មចំពោះទឡ្ហីករណ៍ដែលបានលើកឡើងក្នុងសំណុំរឿង ០០២ នោះ។ ជាក់ស្តែង អត្ថបទនោះ ត្រូវបានដកស្រង់ដើម្បីអុជអាលសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ។ ក្នុងអំឡុងពេលពេលពិភាក្សាគ្នាជាលក្ខណៈឯកជនជាមួយលោក Karnavas ជាច្រើនដង សហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងព្រះរាជអាជ្ញារងអន្តរជាតិ Smith បានបញ្ចេញទស្សនៈស្រដៀងគ្នានេះដែរ។ ទោះជាវាមិនសំខាន់ ឬមិនជាប់ទាក់ទងនឹងបញ្ហានានាពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបានក៏ដោយ ក៏សេចក្តីពិព័ណនាត្រួសៗនេះ គ្រាន់តែបង្ហាញអំពីការលាក់ពុតដ៏ពូកែបំផុតសហព្រះរាជអាជ្ញាអន្តរជាតិ Cayley និងសហព្រះរាជអាជ្ញារងអន្តរជាតិ Smith ដែលបានផ្តល់អត្ថបទដកស្រង់ចេញពីកិច្ចសម្ភាសន៍ជាមួយសារព័ត៌មាន Toronto Star ដោយមិនយកកម្រែឡើយ។ ការដកស្រង់ចេញពីសារព័ត៌មាន Toronto Star មិនមានអ្វីដែលមានតម្លៃជាភ័ស្តុតាងឡើយ កុំថាឡើយមានភាពជាប់ទាក់ទងនោះ។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley គ្រាន់តែមានបំណងអុជអាល និងធ្វើឱ្យប៉ះពាល់ដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិតែប៉ុណ្ណោះ។

48. កថាខណ្ឌ ៧៥-៧៧៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានចោទសហមេធាវីការពារក្តីថាបានអនុវត្តមិនគោរពតាមក្រមសីលធម៌ និងធ្វើប៉ះពាល់ដល់កិច្ចការរដ្ឋបាលរបស់តុលាការតាមរយៈការជូនដំណឹងរបស់លោក មាស មុត ដែលស្នើសុំអនុវត្តសិទ្ធិរបស់គាត់។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley សន្និដ្ឋានថាលោកមាស មុត នឹងមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ខណៈដែលសហមេធាវីការពារក្តី មិនយល់ដូច្នោះឡើយ។ មិនមានការផ្តល់ភ័ស្តុតាងដែលអាចជឿជាក់អំពីចេតនារបស់លោក មាស មុត មុនពេលគាត់ស្វែងរកការប្រឹក្សា និងការតំណាងផ្លូវច្បាប់ពីសហមេធាវីការពារក្តីឡើយ។ ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនបានផ្តល់ភ័ស្តុតាងដែលអាចជឿជាក់បានថាលោក មាស មុត មិនបានដឹងពីសិទ្ធិថែងក្នុងរដ្ឋធម្មនុញ្ញក្នុងការនៅស្ងៀម

មិនឆ្លើយតប ទោះជាកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក កំពុងបន្តទៅមុខ និងសហព្រះរាជអាជ្ញារងអន្តរជាតិ Smith បានណែនាំខុចជាសាធារណៈ និងស្ទើតែលើកទឹកចិត្តខុច កុំឲ្យឆ្លើយសំណួរដែលគាត់យល់ថាដាក់បន្ទុកលើខ្លួនឯងក៏ដោយ។ ទីបី នេះជាតួនាទីរបស់មេធាវីការពារក្តីក្នុងការផ្តល់ការប្រឹក្សាផ្លូវច្បាប់។ ក្នុងនោះ រួមមានសិទ្ធិថែងក្នុងរដ្ឋធម្មនុញ្ញនៃការជំនុំជម្រះក្តីដោយត្រឹមត្រូវ។ ដូចបានលើកឡើងក្នុងកថាខណ្ឌខាងលើ ផ្អែកលើអ្វីដែលបានដឹងពីសំណុំរឿងខុច ការជាប់ពាក់ព័ន្ធដែលលោក មាស មុត ត្រូវបានចោទ ដូចបានបង្ហាញក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអាចមើលបានជាសាធារណៈ និងការស្វះស្វែងយ៉ាងសកម្មដោយបើកចំហជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ដើម្បីឲ្យមានការចោទប្រកាន់លោក មាស មុតនោះ វាជាការចាំបាច់ដែលមេធាវីការពារក្តីដែលមានភាពវាងវៃ និងមានសមត្ថភាព ត្រូវផ្តល់ប្រឹក្សាដល់លោក មាស មុត អំពីសិទ្ធិថែងក្នុងរដ្ឋធម្មនុញ្ញ អំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងរបស់គាត់ បើសិនបើពួកគាត់ស្ថិតក្នុងតួនាទីជាសហមេធាវីការពារក្តីឲ្យលោក មាស មុត។ បើមិនដូច្នេះទេ វាជាការធ្វេសប្រហែសដ៏ធ្ងន់ធ្ងរ។

49. សិទ្ធិថែងក្នុងរដ្ឋធម្មនុញ្ញ ត្រូវតែអនុវត្ត។ វាមិនមានមូលដ្ឋាន និងគួរឲ្យអស់សំណើចក្នុងការអះអាងថានៅពេលដែលក្រុមមេធាវីការពារក្តី ជូនដំណឹង និងផ្តល់ប្រឹក្សាដល់កូនក្តីមួយរូបអំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវ ហើយកូនក្តីរូបនោះ អនុវត្តសិទ្ធិទាំងនេះផ្អែកលើព័ត៌មាន និងការផ្តល់ប្រឹក្សាបែបនេះ ជាការជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការ។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley មិនបានផ្តល់ភ័ស្តុតាងមិនលម្អៀង និងគួរឲ្យជឿជាក់បានដែលបង្ហាញថាសហមេធាវីការពារក្តី ជះឥទ្ធិពល ឬដាក់សម្ពាធលើលោក មាស មុត ហួសហេតុឡើយ។ ដូចបានលើកឡើងក្នុងកថាខណ្ឌខាងលើ វាជាការស្រមើស្រមៃដែលសហព្រះរាជអាជ្ញាអន្តរជាតិ Cayley សន្និដ្ឋានថាលោក មាស មុត ដែលបានដឹងថាគាត់កំពុងត្រូវបានស៊ើបអង្កេត ដើម្បីធ្វើការចោទប្រកាន់ និងនាំខ្លួនមកជំនុំជម្រះក្តី ហើយបានដឹងពីអ្វីដែលកើតឡើងចំពោះខុច និងដឹងពីការចោទជាទូទៅលើរូបគាត់ក្នុងសំណុំរឿង ០០៣ នឹងមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ នោះ។ សហមេធាវីការពារក្តីមិនយល់ដូច្នេះទេ។

## ៣. ពាក្យសុំលះបង់សិទ្ធិ មានប្រសិទ្ធិភាព

50. កថាខណ្ឌ ៧៨-៨៤៖ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley លើកឡើងថាការលះបង់សិទ្ធិ មិនមានលក្ខណៈគ្រប់គ្រាន់ឡើយ ដោយហេតុថាពាក្យសុំនោះ មិនបានផ្តល់ព័ត៌មានជាក់លាក់ និងសម្ងាត់អំពីទំនាក់ទំនងរវាងមេធាវី-កូនក្តីដែលជាប់ទាក់ទងនឹងពាក្យសុំលះបង់សិទ្ធនោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ Cayley ធ្វើការប៉ាន់ស្មានថាជាការចាំបាច់ដែលត្រូវពិគ្រោះយោបល់បន្ថែមជាមួយលោក អៀង សារី ហើយដោយគាត់បានទទួលមរណភាពហើយនោះ ពាក្យសុំលះបង់សិទ្ធិបច្ចុប្បន្នរបស់គាត់ មិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។ ជាទូទៅ ពាក្យសុំលះបង់សិទ្ធិ មិនបញ្ជាក់ពីអង្គហេតុអំពីរឿងក្តីមួយ ឬអំពីព័ត៌មានជាក់លាក់ដែលត្រូវបានពិភាក្សាឡើយ។ ការលះបង់សិទ្ធិមួយផ្នែក ជាកិច្ចការសំខាន់ក្នុងការផ្តល់ប្រឹក្សាដោយហ្មត់ចត់ដល់កូនក្តីអំពីសិទ្ធិ និងអង្គហេតុនានា និងស្ថានភាពនៃរឿងក្តី។ កិច្ចការនេះ ត្រូវអនុវត្តដោយសហមេធាវីការពារក្តីក្នុងសំណុំរឿងនេះ។ ពាក្យសុំលះបង់សិទ្ធិ ដូចជាពាក្យសុំលះបង់សិទ្ធដែលបានផ្តល់ក្នុងសំណុំរឿងនេះ ត្រូវបានប្រើប្រាស់ និងទទួលយកដោយតុលាការជាតិ និងសាលាក្តីអន្តរជាតិ ដូចជានៅ ICTY។

51. ក្រៅពីធ្វើការប៉ាន់ស្មាន សហព្រះរាជអាជ្ញាអន្តរជាតិ Cayley បានផ្តល់ភ័ស្តុតាងមិនអាចជឿជាក់បានដែលបង្ហាញថាលោក អៀង សារី និង/លោក មាស មុត មិនទទួលបានការផ្តល់ប្រឹក្សាសមស្រប មុនពេលចុះហត្ថលេខាលើពាក្យសុំលះបង់សិទ្ធរបស់ពួកគាត់ឡើយ។ នៅអ.វ.ត.ក មិនមានលក្ខខណ្ឌដែលតម្រូវឲ្យអង្គភាពគាំពារការពារក្តី ចាត់តាំងមេធាវីឯករាជ្យដើម្បីស្នើសុំយោបល់ឯករាជ្យ ឬយោបល់បន្ថែមពីលោក អៀង សារី ឬមាស មុត ឡើយ។ អ្វីដែលច្បាស់បំផុតនោះគឺប្រធានអង្គភាពគាំពារការពារក្តី ដែលជាមេធាវីមួយរូប និងបានអនុវត្តការងារនៅ ICTR បានជួបជាមួយលោក មាស មុត ជាលក្ខណៈឯកជន និងដោយមិនមានវត្តមានមេធាវីការពារក្តី ក្នុងគោលបំណងមួយចំនួន ក្នុងនោះដើម្បីបញ្ជាក់ថាលោក មាស មុត (ក) ពិតជាស្នើសុំឲ្យចាត់តាំងសហមេធាវីការពារក្តី (ខ) គាត់បានអនុវត្តការលះបង់សិទ្ធិ និងការជូនដំណឹង (គ) ស្ថានភាពនានាបន្ទាប់ពីការលះបង់សិទ្ធិ និងការជូនដំណឹង។

52. ការពោលអះអាងថាពាក្យសុំលះបង់សិទ្ធិ មិនមានលក្ខណៈគ្រប់គ្រាន់ដោយសារលោក អៀងសារី បានទទួលមរណភាពនោះ ជាឧទាហរណ៍មួយទៀតដែលបង្ហាញថាសហព្រះរាជអាជ្ញាអន្តរជាតិ Cayley គ្រាន់តែលើកឡើងដោយឥតប្រយោជន៍។ មិនមានយុត្តិសាស្ត្រនៅ អ.វ.ត.ក ដែលគាំទ្រជំហរនេះឡើយ។ ជាក់ស្តែង បើសិនមានច្បាប់ដូចអ្វីសហព្រះរាជអាជ្ញាអន្តរជាតិ Cayley អះអាងនោះ ពាក្យសុំលះបង់សិទ្ធិរបស់កូនក្តី នឹងលែងមានសុពលភាពជាស្វ័យប្រវត្តិបន្ទាប់ ពួកគាត់ទទួល

មរណភាព។ ការប៉ាន់ស្មានដែលថាអាចមានលទ្ធភាពស្តួចស្តើង ដែលសហមេធាវីការពារក្តី ស្នើសុំការណែនាំបន្ថែម និងការយល់ព្រមពីលោក អៀង សារី នោះ មិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាពាក្យសុំលះបង់សិទ្ធិនេះ មិនមានសុពលភាព ឬមានលក្ខណៈគ្រប់គ្រាន់ឡើយ។

## III. សេចក្តីសន្និដ្ឋាន និង ដំណោះស្រាយដែលបានស្នើសុំ

53. លោក មាស មុត មានសិទ្ធិជាសារវ័ន្តក្នុងការជំនុំជម្រះក្តីដោយត្រឹមត្រូវដើម្បីទទួលបានការតំណាងពីមេធាវីដែលគាត់ជ្រើសរើសដោយខ្លួនឯង[48]។ លោក មាស មុត មានសិទ្ធិចែងក្នុងរដ្ឋធម្មនុញ្ញក្នុងការជំទាស់មិនផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២/០១ ជាពិសេសនៅពេលយល់ឃើញថាគាត់ជាជនសង្ស័យដែលត្រូវបានផ្តោតគោលដៅ និងស្ថិតក្រោមការស៊ើបអង្កេតដោយ ក.ស.ច.ស ក្នុងសំណុំរឿង ០០៣ ។ វាជាក់ច្បាស់ថាសហព្រះរាជអាជ្ញាអន្តរជាតិ Cayley នឹងព្យាយាមជំរុញឱ្យលោក មាស មុត ឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនគាត់ បើសិនលោក មាស មុត ផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២។ សហមេធាវីការពារក្តី បានពិភាក្សាជាមួយលោក អៀង សារី និងលោក មាស មុត អំពីទំនាស់ផលប្រយោជន៍ ដែលអាចកើតឡើងក្នុងរឿងក្តីរបស់ពួកគាត់បណ្តាលមកពីការតំណាកូនក្តីពីរូបក្នុងពេលតែមួយ។ សហមេធាវីការពារក្តី លោក អៀង សារី និងលោក មាស មុត មានការពេញចិត្តដោយសារមិនមានទំនាស់នៃផលប្រយោជន៍ ដែលអាចកើតឡើងរវាងសំណុំរឿងទាំងពីរនេះឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញគ្រប់គ្រាន់ និងមិនបានបង្ហាញភ័ស្តុតាងជាក់ស្តែងថាទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ពិតជាកើតមាន ជាអង្គហេតុដើម្បីជំទាស់ទៅនឹងការតែងតាំងសហមេធាវីការពារក្តីដើម្បីតំណាងលោក មាស មុត ក្នុងសំណុំរឿង ០០៣ ឡើយ។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងខាងលើ ក្រុមមេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់សហចៅក្រមស៊ើបអង្កេត សូមមេត្តា**ច្រានចោល**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងបញ្ជាក់ពីការតែងតាំងសហមេធាវីការពារក្តីដោយអង្គភាពគាំពារការពារក្តី។

---

[48] រដ្ឋធម្មនុញ្ញកម្ពុជា, មាត្រា ៣៨; កិច្ចព្រមព្រៀង, មាត្រា ១៣(១); ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៥(ថ្មី)(ឃ)។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ **២០១៣**

| | |
|---|---|
| ________________ | ________________ |
| **អាង ឧត្តម** | **Michael G. KARNAVAS** |